# ដំណើរជីវិត



រៀបរៀងដោយ

ភិក្ខុវជិរប្បញ្ញោ សាន សុជា

សម្រាប់ជាធម្មទាន

ព.ស. ២៥៥១

# មាតាបិតាមានឈ្មោះ៤យ៉ាង



ភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងញោមប្រុសស្រី

១- ជា "ព្រះព្រហ្ម" របស់កូន

២- ជា "បុព្វទេវតា" របស់កូន

៣- ជា "បុព្វាចារ្យ" របស់កូន

៤- ជា "អាហុនេយ្យបុគ្គល" របស់កូន

# ពាក្យផ្តើម

**ដំណើរជីវិត** គឺជាឈ្មោះនៃសៀវភៅថ្មីមួយទៀត ដែលខ្ញុំបានរៀបរៀងឡើង ក្នុងកាលដែលខ្ញុំមានអាយុ ៣១ ឆ្នាំ បន្ទាប់ពីបានបោះពុម្ពចែកផ្សាយនូវសៀវភៅ **ព្រះធម្មបទ ៣១គាថា** រួចហើយ។

សៀវភៅ **ដំណើរជីវិត** នេះ ខ្ញុំបានចាប់ផ្តើមសរសេរ នៅប្រទេសកម្ពុជា ហើយបានបញ្ចប់ដោយសព្វគ្រប់នៅ ប្រទេសអូស្ត្រាលី ក្នុងកំលុងពេលដែលខ្ញុំមកបង្រៀន ព្រះអភិធម្មត្ថអំពីរូបបរមត្ថ បរិច្ឆេទទី ៦ ដល់ពុទ្ធបរិស័ទ នៅក្នុងអាគារសមាគមខ្មែរ នាទីក្រុងម៉ែលបិន ចាប់ពីថ្ងៃ ព្រហស្បតិ៍ ៦រោច ខែចេត្រ ឆ្នាំច អដ្ឋស័ក ព.ស.២៥៥០ ដល់ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១ ដែលជាដំណើរលើកទីពីររបស់ខ្ញុំមកកាន់ ប្រទេសអូស្ត្រាលី។

ដំណើរជីវិត គឺជាបទពិចារណាទាក់ទងនឹងរឿងជីវិត របស់មនុស្សគ្រប់គ្នា។

ជីវិត ប្រៀបដូចជាការធ្វើដំណើរផ្លូវឆ្ងាយ ហើយអ្នកធ្វើដំណើរគ្រប់គ្នា ចាំបាច់ត្រូវតែមានគោលដៅ និងស្បៀងឬជាគ្រឿងប្រដាប់សម្រាប់ការពារខ្លួនផងៗ

លើផែនដីនេះ មិនមែនមានសុទ្ធតែផ្កាកោយកាយគ្រប់កន្លែងទេ ហើយក៏មិនមែនមានសុទ្ធតែបន្លាគ្រប់ទីកន្លែងដែរៗ ដូច្នេះការធ្វើដំណើរផ្លូវឆ្ងាយ មិនមែនទាល់តែរើសបន្លាឲ្យអស់ពីផែនដីសិនទើបដើរកើតនោះទេ យើងគ្រាន់តែត្រូសត្រាយផ្លូវឲ្យល្មមតែដើររួច ឬត្រូវពាក់ស្បែកជើងដែលមានកម្រាស់ជាមធ្យម យើងក៏អាចដើរទៅបានយ៉ាងស្រួលៗ

យ៉ាងណាមិញ ជុំវិញជីវិតរបស់យើងម្នាក់ៗ ក៏មិនមែនមានសុទ្ធតែផ្កាគឺភាពផ្អែមល្ហែម ការសរសើរ ការរាប់អាន ការបានលាភ ការបានយស និងសេចក្ដីសុខគ្រប់យ៉ាងទេ ហើយក៏មិនមែនមានសុទ្ធតែបន្លាគឺភាពល្វីងជូរចត់ការនិន្ទា ការបាត់លាភ ការបាត់យស និងសេចក្ដីទុក្ខតែរហូតនោះដែរ សភាវៈទាំងពីរផ្នែកនេះ តែងតែមានជាហូរហែ

ដោយផ្លាស់ប្តូរគ្នាទៅវិញទៅមក ឥតមានឈប់ឈរឡើយ ហើយសត្វលោកគ្រប់គ្នា សុទ្ធតែត្រូវមានដំណើរឆ្លងកាត់នូវសភាវៈទាំងពីរនេះដោយចៀសមិនផុត។

ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ គឺជាមាគ៌ាដ៏ជាក់លាក់ ដែលជំបូងបានបង្រៀនឲ្យសត្វលោក មានការជឿជាក់លើខ្លួនឯង ដើម្បីឲ្យសត្វលោកខ្លួនឯងផ្ទាល់មានស្មារតីនិងបញ្ញា ដ៏មុតមាំហ៊ានដើរឆ្លងកាត់នូវព្យុះជីវិត ដោយទឹកមុខញញឹម ព្រោះបញ្ញា គឺជាអាវុធដ៏ឧត្តម និងជាគ្រឿងក្រោះយ៉ាងអស្ចារ្យអាចការពារសត្វលោកឲ្យឆ្លងផុតពីសង្សារទុក្ខបាន។

ដោយអំណាចនៃធម្មទាននេះ សូមពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាននិងគ្រប់វ័យ បាននូវបទពិចារណាដ៏សមស្រប សម្រាប់ជីវិតជានិច្ចតរៀងទៅ។

**សូមអនុមោទនា !!!**

*ម៉ែលប៊ិន ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំកុរ ទោស័ក ព.ស.២៥៥១*

ភិក្ខុវជិរប្បញ្ញោ **សាន សុជា**

# មាតិកាធម៌


ពាក្យប្រារព្ធ ........................................ ក

១.ជីវិត ........................................ ១

២.តុល្យភាពនៃជីវិត ........................................ ៣

៣.ជីវិតនិងពេលវេលា ........................................ ៨

៤.ធម្មតារបស់ជីវិត ........................................ ១៣

៥.ជីវិតស្អុកលោក ........................................ ៣២

៦.ជីវិតអន្ទការ ........................................ ៣៤

៧.ក្តីងជីវិត ........................................ ៣៩

៨.ជីវិតនិងឧបសគ្គ ........................................ ៤៩

៩.ជីវិតអ្នកបម្រើសម័យ ........................................ ៥៥

១០.ជីវិតមានផល ........................................ ៥៨

១១.ជីវិតគោចាស់ ........................................ ៦១

១២.កំណាព្យផ្សេងៗ ........................................ ៦៦

១៣.អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ ........................................ ៨៣

១៤.ចំនួនសៀវភៅដែលខ្ញុំបានរៀបរៀង ........................................ ៨៤

១៥.ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយ ........................................ ៨៥

១៦.ឈ្មោះសប្បុរសជនអ្នកបរិច្ចាគប្រាក់ ........................................ ៨៦

# ១~ជីវិត

ពាក្យថា **ជីវិត** សំដៅដល់ប្រមាណនៃអាយុ ឬការរស់នៅរបស់សត្វទាំងឡាយគ្រប់ៗគ្នា ស្ថិតនៅក្នុងលោកសន្និវាស។

ម្យ៉ាងទៀត **ជីវិត** សំដៅដល់រូបកាយ និងចិត្តវិញ្ញាណរបស់សត្វលោក ឬបើនិយាយឲ្យងាយស្តាប់ គឺខ្លួនប្រាណរបស់សត្វលោកគ្រប់គ្នា ដែលកំពុងមានសកម្មភាពនេះឯង។

ម្យ៉ាងទៀត **ជីវិត** មិនគឺអ្វីដទៃក្រៅអំពីការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការដឹងផោដ្ឋព្វៈ និងការដឹងរឿងរ៉ាវផ្សេងៗ នោះឡើយ នៅពេលការឃើញ ការឮជាដើមលែងមានហើយ ក៏សន្មតថា ជាពេលអស់ជីវិត ឬពេលស្លាប់នោះឯង។

ដើមរុក្ខជាតិទាំងឡាយ យើងក៏អាចនិយាយថារស់ ឬស្លាប់បានដែរ តែមិនមានជីវិតទេ ព្រោះជាធម្មជាតិដែលកើតឡើងអំពីសមុដ្ឋានតែមួយ គឺឧតុ (រដូវ) ឯជីវិតសត្វលោកកើតឡើងពីសមុដ្ឋានបួនគឺ កម្ម ចិត្ត ឧតុ និងអាហារ។

រូបកាយខ្ញុំនេះណា ញាតិវង្សានៅរាប់អាន
ព្រោះនៅមានវិញ្ញាណ ទើបមិនមានអ្នកណាខ្លាច។
គ្រាន់តែដាច់ខ្យល់ភ្លឹង រលត់ឈឹងអស់អំណាច
តែត្រូវគេភ័យខ្លាច មិនអាចទុកនៅគេហា។
គេចោលនៅទីព្រៃ ដាច់អាល័យគ្មានរក្សា
ឬដុតក្នុងប៉ាឆា ឱ! អនិច្ចារូបខ្ញុំអើយ !!!

ភិក្ខុវជិរប្បញ្ញោ ស.ស.ឌ

# ២. តុល្យភាពនៃជីវិត

គ្រប់បុថុជ្ជន ដែលមិនបានស្តាប់នូវធម៌របស់ព្រះអរិយៈ មិនត្រឹមតែប្រកាន់មាំក្នុងនាមរូបនេះប៉ុណ្ណោះទេ ថែមទាំងមានសេចក្តីវង្វេងភ្លេចភ្លាំងស្មារតី ដោយហេតុច្រើនយ៉ាងទៀតគឺ

ក-វង្វេងព្រោះទ្រព្យសម្បត្តិ ព្រោះតែទ្រព្យ ធ្វើឲ្យមនុស្សលោកដាច់សីលទាំងស្រស់ៗ រហូតធ្វើឲ្យមានការលើកកម្ពស់ខ្លួនឯង ហើយមើលងាយមើលថោកដល់អ្នកក្រខ្សត់ទ្រព្យសម្បត្តិទៀតផងៗ

ខ-វង្វេងព្រោះយសសក្តិ យសសក្តិ ធ្វើឲ្យមនុស្សខ្លះមានមានះកាន់តែខ្លាំងឡើង អាចធ្វើឲ្យលែងចេះគោរពឱនលំទោនចំពោះមាតាបិតា បាស់គ្រូឱ្យាចារ្យ និងអ្នកដែលចម្រើនដោយគុណមានសីលគុណជាដើមៗ

គ-វង្វេងព្រោះចំណេះដឹង ការមានចំណេះដឹង មិនមែនជារឿងអាក្រក់ទេ តែបើយកទៅប្រើប្រាស់មិនល្អ វាក៏អាចសម្លាប់ម្ចាស់របស់វាបានដែរ ដូចជាអ្នកដែលបាន សិក្សាវិជ្ជាផ្លូវលោកខ្ពង់ខ្ពស់មួយចំនួន តែងមានការប៉ាន់ ស្មានគុណភាពរបស់ព្រះពុទ្ធសាសនា តាមរយៈពុទ្ធសា- សនិកដែលមានកម្រិតវប្បធម៌ទាប ហើយក៏គិតថា ក្នុង ព្រះពុទ្ធសាសនា មិនមានអ្វីពិសេសជាងចំណេះដែលខ្លួន មានឡើយ គំនិតបែបនេះ ធ្វើឲ្យបុគ្គលទាំងនោះកាន់តែឃ្លាត ឆ្ងាយពីធម៌របស់ព្រះសម្មាសម្ពុទ្ធ រហូតធ្វើឲ្យគេក្លាយទៅ ជាមនុស្សមិច្ឆាទិដ្ឋិព្រោះតែចំណេះដឹងនោះក៏សឹងមានៗ

ឃ-វង្វេងព្រោះរូបសម្បត្តិ ព្រោះតែរូបសម្បត្តិល្អ ធ្វើឲ្យមនុស្សមានការរើសអើង ដល់អ្នកដែលមានរូប សម្បត្តិមិនល្អ ព្រោះមនុស្សចូលចិត្តមើលតែសម្បកខាង ក្រៅ តែបើគេបានពិនិត្យទៅដល់ផ្នែកខាងក្នុងនៃរូបរាងកាយ

គេនឹងឃើញច្បាស់ថា គ្រប់មនុស្សទាំងអស់សុទ្ធតែស្លាយ ផង់មូត្រផង់លាមកត្រាច់ទៅដូចគ្នា។

**៨-រង្វេងព្រោះគ្នីគ្នា** ព្រោះតែបក្សពួក ធ្វើឲ្យមនុស្ស មានការប្រមាទ មិនព្រមប្រព្រឹត្តព្រហ្មចរិយធម៌ មានទាន សីលជាដើម ក្នុងគំនិតរបស់គេហាក់បីដូចជាគិតថា ពេល ធ្វើដំណើរទៅកាន់បរលោក បក្សពួកនិងគ្នីគ្នាទាំងអស់នោះ ទៅទទួលរងទុក្ខជំនួសអ៊ីចឹងឯង។

សរុបសេចក្ដីគឺថា សត្វលោកនេះ តែងតែមានការ ពឹងផ្អែកទៅលើអ្វីៗដែលខ្លួនមាន ហើយមានសេចក្ដីប្រៀប ធៀបនឹងអ្នកដទៃ បើឃើញថាខ្លួនមានអ្វីពិសេសជាងគេ ក៏ ត្រេកអរនិងជោរបុានចិត្ត ហើយបើឃើញថាខ្លួនអន់ជាងអ្នក ដទៃ ក៏មានសេចក្ដីខកចិត្តនិងរំខានផ្លូវចិត្ត។

តាមពិតសត្វលោកទាំងអស់ ទាំងសត្វនៅក្នុង អបាយភូមិ និងសត្វនៅក្នុងសុគតិភូមិ ទាំងអ្នកមាន និង

អ្នកក្រ ទាំងបុគ្គលពាល និងបុគ្គលជាបណ្ឌិត តែងមាន សេចក្ដីសុខនិងសេចក្ដីទុក្ខ ច្រើនឬតិចមិនស្មើគ្នា តែមាន សភាពស្មើគ្នាក្នុងលក្ខណៈពីរយ៉ាងគឺ មានការកើតជា ខាងដើម និងមានការស្លាប់ទៅវិញជាខាងចុង នេះគឺជា តុល្យភាពនៃជីវិត។

រឿងរបស់ជីវិតនេះ មិនខុសអំពីរឿងរបស់កុនឬ ល្ខោនដែលគេលេងតាមរោងឡើយ មុននឹងឡើងទៅសម្ដែង សុទ្ធតែជាកស្ត្រសាមញ្ញដូចគ្នាទាំងអស់ មិនអាចក្លាយជា ស្ដេច ជាអាមាត្យ ជាលោកសេដ្ឋីមែនទែនដោយហេតុ ត្រឹមតែការឡើងលើឆាក ហើយស្រែកប្រកាសនាមនោះទេ នៅពេលដែលរឿងល្ខោនចប់ ភាពដើមយ៉ាងណា គឺនឹង ក្លាយទៅជាយ៉ាងនោះវិញដដែល។

បើអ្នកដើរតួធ្វើជាលោកសេដ្ឋី ក្នុងរឿងល្ខោនប្រកាន់ ថាខ្លួនឯងជាលោកសេដ្ឋីមែនទែន ខួរក្បាលរបស់អ្នកនោះ

ពិតជាមានបញ្ហា តែបើដឹងខ្លួនថា តំណែងសេដ្ឋីនេះ គ្រាន់តែជាបញ្ញត្តិក្នុងរឿងល្ខោន មិនមែនជារឿងពិត ដូច្នោះអ្នកនោះបាត់ថា ជាមនុស្សត្រឹមត្រូវ មិនវង្វេងស្មារតី។

យ៉ាងណាមិញ សត្វលោកយើងគ្រប់ឋានៈទាំងអស់ទីបំផុត ត្រូវចាកចេញពីឆាកល្ខោនជីវិតនេះដូចគ្នាដោយបាតដៃទទេ ដោយឥតមានបានអ្វីសូម្បីតិចតួចអំពីបច្ចុប្បន្នកាលនេះឡើយ។

កាលបើពិចារណាឃើញយ៉ាងនេះហើយ គួរឬ ដែលនឹងប្រកាន់ថា ខ្លួនឯងគ្រាន់បើជាងអ្នកដទៃ រហូតដល់មានការមើលងាយអ្នកដទៃដោយប្រការផ្សេងៗ ទាំងដែលខ្លួនឯងក៏កំពុងតែប្រឈមមុខនឹងមច្ចុរាជដែរនោះ ?

គួរតែអាណិតអាសូរ និងសង្គ្រោះគ្នាទើបល្អ។

ធម្មជាតណាកើតជាធម្មតា គង់ប្រែអនិច្ចាសព្វសកល
កើតហើយរលត់អស់គ្មានសល់ ព្រោះត្បិតជាផលនៃបច្ច័យ។

ភិក្ខុវជិរប្បញ្ញោ ស.ស.ឌ

# ៣-ជីវិតនិងពេលវេលា

គេតែងនិយាយថា "ពេលវេលា គឺជាមាសប្រាក់" តាមពិត ពាក្យនិយាយនេះ មិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះថាមាសប្រាក់ដែលបាត់បង់ទៅ ជួនកាលអាចរកមកវិញបាន តែពេលវេលាដែលកន្លងទៅ មិនអាចត្រឡប់មកវិញបានទេ។

ដូច្នេះ តម្លៃនៃពេលវេលា មិនអាចរករបស់ខាងក្រៅខ្ទង់ណាមួយមកវាស់វែងបានឡើយ។ បើពិចារណាឲ្យជិតដល់ទៅ មានតែជីវិតប៉ុណ្ណោះ ដែលអាចវាស់វែងទៅនឹងពេលវេលាបាន ព្រោះថា ជីវិតក៏ជារបស់ដែលបាត់បង់ហើយ មិនអាចត្រឡប់មកវិញបានដូចជាពេលវេលាដែរ។

តាមន័យនៃបរមត្ថធម៌ ពេលវេលាជារបស់ដែលមិនមានដោយសភាវៈ ត្រឹមតែជាការបញ្ញត្តិ និងកំណត់ចំណាំឲ្យដឹងគ្នាតែប៉ុណ្ណោះ ឯរបស់ដែលមានពិត គឺការ

កើតនិងការរលត់ទៅនៃតួជីវិតនេះឯង បើមិនមានការកើតឡើង និងការរលត់ទៅនៃតួជីវិតនេះទេ ក៏មិនមានការបញ្ញត្តិ ឬកំណត់ចំណាំពេលវេលាសម្រាប់ហៅដែរ។

ពេលវេលាកន្លងទៅមួយថ្ងៃ ជីវិតក៏ត្រូវបាត់បង់អស់មួយថ្ងៃ ពេលវេលាកន្លងទៅមួយខែ ជីវិតក៏ត្រូវបាត់បង់អស់មួយខែ ពេលវេលាកន្លងទៅមួយឆ្នាំ ជីវិតក៏ត្រូវបាត់បង់អស់មួយឆ្នាំ ពេលវេលាកន្លងទៅច្រើនប៉ុណ្ណា ជីវិតក៏ត្រូវបាត់បង់ទៅច្រើនប៉ុណ្ណោះ ព្រោះហេតុដូច្នោះ មិនគួរទុកដាក់ពេលវេលាស្មើត្រឹមតែមាសប្រាក់ឡើយ។

យើងអាចនិយាយបានថា ពេលវេលា គឺជាអាយុជីវិត, ដូច្នេះទើបពេលវេលាមានតម្លៃសម្រាប់បំពេញកិច្ចការផ្សេងៗទៀត ក្រៅពីការរកមាសប្រាក់ ព្រោះជីវិតនេះមិនមែនអស់នូវទុក្ខកង្វល់ ដោយគ្រាន់តែមានមាសប្រាក់នោះឡើយ ប្រសិនបើមាសប្រាក់ ពិតជាអាចដោះស្រាយសេចក្តីទុក្ខគ្រប់យ៉ាងបានមែន ម្ល៉េះសមពួកអ្នកមាន

ទ្រព្យច្រើនលែងចេះឈ្លោះទាស់ទែងគ្នា សម្លាប់គ្នា និងការធ្វើអត្តឃាតទៅហើយ។

ក្នុងសង្គម ធ្លាប់បានឮថា មនុស្សជាច្រើន ពេលដែលគេបបួលឲ្យស្តាប់ធម៌ ឬសិក្សាព្រះធម៌ តែងតែឆ្លើយថា "ចង់ដែរ តែមិនមានពេល ព្រោះជាប់ការងារ" នេះគ្រាន់តែជាពាក្យដោះសាប៉ុណ្ណោះ។

សួរថា បើពិតជារវល់មែន ហេតុអ្វីក៏មានពេលកម្សាន្តច្រើនម៉្លេះ? ដូចជា ពេលដើរលេង ពេលជប់លៀង ពេលស្តាប់ចម្រៀង ពេលនិយាយដើមគេ ពេលមើលទូរទស្សន៍ជាដើម។

ដូច្នេះ ការឆ្លើយថា "ដែលខ្ញុំស្តាប់ ឬសិក្សាធម៌មិនបានព្រោះតែខ្ញុំរវល់ពេក" នេះ គឺជាចម្លើយមិនសមហេតុផលទេ ចម្លើយដែលត្រូវគួរឆ្លើយថា "ការដែលខ្ញុំស្តាប់ ឬ សិក្សាធម៌មិនបាន ព្រោះតែខ្ញុំមិនមានសទ្ធា" នេះទើបសម

ហេតុផល ព្រោះថាកាលណាមានសទ្ធាហើយ ពិតជាអាច ឆ្លៀតពេលបានគ្រប់ៗគ្នាទាំងអស់ បើទុកជាមិនអាចទៅ ស្តាប់ ឬសិក្សាផ្ទាល់អំពីព្រះធម្មកថិក ក៏អាចឆ្លៀតស្តាប់ តាមវិទ្យុ ឬកាសែត ឬក៏អានសៀវភៅធម៌នៅតាមផ្ទះបាន ខ្លះមិនខានៗ

អ្នកខ្លះទៀត មិនមែនថាគេមិនចង់ស្តាប់ មិនចង់ សិក្សាទេ តែគេមានគំនិតជាទុទិដ្ឋិនិយមថា ពេលដែលនៅ វ័យក្មេង គេមិនទាន់ត្រូវការធម៌ទេ ព្រោះត្រូវប្រកបមុខ-របរចិញ្ចឹមជីវិត ដល់ពេលចាស់ គេមុខជានឹងចូលទៅរកធម៌ មិនខាន ការនិយាយបែបនេះហាក់ដូចជាច្បាស់ក្នុងចិត្តថា គេ មិនស្លាប់ពីក្មេងឡើយៗ

សូមផ្តាំមនុស្សគ្រប់ជំនាន់ថា យើងអាចដាក់កាល វិភាគសម្រាប់ធ្វើការងារផ្សេងៗបាន តែមិនអាចដាក់កាល វិភាគសម្រាប់ស្លាប់បានទេ បើទុកជាចង់ដាក់ ក៏ដាក់

មិនត្រូវដែរ វៀរលែងតែមនុស្សធ្វើអត្តឃាត ដោយ សេចក្ដីថា ទោះបីជាយើងរស់រហូតគ្មានពេលចូលបន្ទន់ក៏ដោយ តែមិនអាចរស់រហូតដល់គ្មានថ្ងៃស្លាប់នោះទេ។

អ្នកណាទុកពេលវេលាស្មើនឹងមាសប្រាក់ អ្នកនោះ ឈ្មោះថា ទុកជីវិតខ្លួនឯងស្មើនឹងមាសប្រាក់ ហើយស្ម័គ្រចិត្ត ធ្វើជាទាសកររបស់មាសប្រាក់រហូត។

តាមពិត ជីវិតនេះថ្លៃណាស់ មិនមែនមានតម្លៃ ស្មើតែនឹងមាសប្រាក់ឡើយ ព្រោះថា បើទុកជាមាននរណា ម្នាក់យកលុយច្រើនប៉ុណ្ណាមកទិញជីវិតយើង ៗ ពិតជាមិន ព្រមលក់ជាដាច់ខាត។

| | |
|---|---|
| ថេរៈវេលាចេះតែកន្លង | ១០ឆ្នាំ១០ដងមិនយឺនយូរឡើយ |
| ចង់បានសម្រេចត្រូវប្រឹងឱ្យហើយ | បើនៅកន្តើយពិតជាអស់ពេល។ |
| | ភិក្ខុវជិរប្បញ្ញោ ស.ស.ឌ |

# ៤-ធម្មតារបស់ជីវិត

ជីវិត គឺជាធម្មជាតិ ដែលរួមផ្សំទៅដោយរូបធាតុ និងនាមធាតុ ជាសង្ខតធម៌ ជាធម៌ដែលកើតពីបច្ច័យ មិនមែនស្ថិតក្រោមអំណាច ឬការបង្គាប់បញ្ជារបស់បុគ្គលណាម្នាក់ឡើយ កាលកើតឡើងហើយ តែងជួបប្រទះនូវហេតុធម្មតាដែលមិនអាចទប់ស្កាត់បាន ដូចជា ចាស់ ឈឺ ស្លាប់ជាដើម។

ដើម្បីឲ្យចិត្តរបស់យើងម្នាក់ៗ ហ៊ានទទួលស្គាល់នូវការពិត និងកុំឲ្យមានការតក់ស្លុតក្នុងជីវិត ទើបព្រះមានព្រះភាគទ្រង់បង្រៀនឲ្យយើញនូវខ្សែជីវិតនេះ ស្ថិតក្រោមលក្ខណៈធម្មតា ៥ យ៉ាង គឺឲ្យពិចារណាថា

១. ជរាធម្មោម្ហិ ជរំ អនតីតោ អាត្មាអញតែងមានការចាស់ជរាជាធម្មតា មិនអាចកន្លងនូវការចាស់ជរាបានឡើយ។

អ្នកវិទ្យាសាស្ត្រក្នុងពិភពលោក គេបានទឹងកំពុងស្វះស្វែងរកវិធីកែរូបសម្ផស្ស ធ្វើយ៉ាងណាដើម្បីឲ្យគេមើលឃើញថា នៅស្អាត ក្មេងជាងវ័យ ដើម្បីប្រមូលយកលុយអំពីមនុស្សដែលមិនចង់ចាស់រាប់រយលាននាក់ៗ

អ្នកដែលមិនចង់ចាស់ទាំងអស់នោះ ប្រសិនបើមិនបានស្លាប់ពីក្មេងទេ ទីបំផុតគង់តែក្លាយជាយាយតាទាំងអស់ដោយឥតមានសេសសល់ម្នាក់ឡើយ ទោះបីជារត់ទៅនៅទីណា ឬប្រើវិធីអ្វីក៏ដោយ លទ្ធផលដែលគេទទួលបាន គឺសេចក្ដីខកចិត្តប៉ុណ្ណោះឯងៗ

ការដែលព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀន ឲ្យឃើញថាជីវិតរបស់យើងម្នាក់ៗ តែងតែចូលទៅកាន់ការចាស់ជរានេះ មិនមែនបានន័យថា ឲ្យយើងបណ្ដែតបណ្ដោយឲ្យជីវិតចាស់ទៅដោយឥតអំពើដូចជាគោចាស់ទេ គឺឲ្យយើងមានស្មារតីប្រឹងប្រែងកសាងគុណធម៌ឲ្យបានច្រើន តាំងតែពីខ្លួននៅក្មេង

ព្រោះថា កាលបើខ្លួនចាស់ទៅ ប្រាជ្ញាស្មារតីត្រូវតែចុះទន់ខ្សោយដែរ មិនរាងវៃដូចខ្លួននៅក្មេងទៀតឡើយ។

ម្យ៉ាងទៀត សេចក្ដីនៃមាតិកាធម៌នេះ ព្រះអង្គមានព្រះបំណង មិនឲ្យសត្វលោកស្រវឹងក្នុងវ័យ ដែលហៅថា **វយមទោ** និងមិនឲ្យសត្វលោកមានភាពតក់ស្លុត នឹកស្ដាយក្រោយនៅពេលដែលវ័យនិងសម្រស់បាត់បង់ទៅ។

**២. ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ** អាត្មាអញតែងមានព្យាធិ គឺជម្ងឺតម្កាត់ជាធម្មតា មិនអាចកន្លងនូវព្យាធិគឺជម្ងឺតម្កាត់បានឡើយ។

ព្យាធិ គឺជម្ងឺតម្កាត់ផ្សេងៗ ក៏គឺជារបស់ធម្មតាដែលតែងកើតមានក្នុងរូបកាយរបស់សត្វលោកគ្រប់ៗគ្នា ដែលថាសត្វលោកណាម្នាក់ មិនមានជម្ងឺតម្កាត់នោះមិនមានសោះឡើយ គ្រាន់តែប្លែកគ្នាត្រង់ថា ឈឺតិចឬច្រើនប៉ុណ្ណោះ។

ការផារគ្រប់បែបយ៉ាងទាំងអស់ មានតែមនុស្សដែល

មានសុខភាពល្អប៉ុណ្ណោះ ទើបអាចបំពេញឲ្យបានគ្រប់ជ្រុងជ្រោយទៅបាន ដូច្នេះការងារជាប្រយោជន៍ដែលគួរធ្វើត្រូវតែធ្វើឲ្យហើយ មុនពេលដែលជម្ងឺតម្កាត់ណាមួយត្រូវកើតឡើងចំពោះខ្លួនរបស់យើង។

ម្យ៉ាងទៀត សេចក្តីនៃមាតិកាធម៌នេះ ព្រះអង្គមានព្រះបំណង មិនឲ្យសត្វលោកស្រវឹងក្នុងការមិនមានរោគដែលហៅថា **អារោគ្យមទោ** និងមិនឲ្យសត្វលោកមានភាពតក់ស្លុត ទឹកកណ្តោចកណ្តែងនៅពេលដែលធ្លាក់ខ្លួនឈឺដោយជម្ងឺណាទីមួយដែលទឹកស្មានមិនដល់។

៣. **មរណធម្មោម្ហិ មរណំ អនតីតោ** អាត្មាអញតែងមានមរណៈគឺសេចក្តីស្លាប់ទៅវិញជាធម្មតា មិនអាចកន្លងនូវសេចក្តីស្លាប់បានឡើយ។

ក្នុងបដិច្ចសមុប្បាទ ព្រះមានព្រះភាគត្រាស់សម្តែងថា **ជាតិប្បច្ចយា ជរាមរណំ** ជរានិងមរណៈកើតមានព្រោះមាន

ជាតិជាបច្ច័យ។

របស់ណាកើតជាខាងដើម របស់នោះតែងមានការបែកធ្លាយទៅវិញនាពេលចុងបញ្ចប់ ដោយហាមឃាត់មិនបានជាដាច់ខាត ទោះបីអំណាចរបស់ទេវតា ឬការប៉ុនប្រសប់របស់អ្នកវិទ្យាសាស្ត្រ ក៏មិនអាចហាមឃាត់បានឡើយ កាលពីអតីតយ៉ាងណាមិញ បច្ចុប្បន្ននិងអនាគតក៏នៅតែយ៉ាងនោះ. ទាល់តែមិនមានការកើតជាខាងដើម ទើបមិនមានការរលត់បែកធ្លាយទៅវិញជាខាងចុង ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ជាបដិលោម ក្នុងបដិច្ចសមុប្បាទថា **ជាតិនិរោធា ជរាមរណំ** ជរានិងមរណៈរលត់ ព្រោះរលត់នៃជាតិ។

ក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ ត្រង់ទំព័រ១០៨ ព្រះមានព្រះភាគទ្រង់ឧបមានូវជីវិតរបស់សត្វលោកដូច្នេះថា

**ទហរាបិ ច យេ ទុឡ្ហា យេ ពាលា យេ ច បណ្ឌិតា**

**អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។**

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី

ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី

ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅ

ពីខាងមុខ។

**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ**

**ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ**

**សព្វំ ភេទនបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។**

កាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ

ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី កាជន៍

ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត

យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាង

នោះដែរ។

ការដែលសត្វលោកភ័យខ្លាចសេចក្ដីស្លាប់ ព្រោះតែមិនបានស្គាល់សេចក្ដីស្លាប់ឲ្យបានច្បាស់ តែបើពិចារណាឲ្យបានរឿយៗ ពិតជាឃើញថាសេចក្ដីស្លាប់គឺជារបស់ធម្មតាដោយពិត, ឧបមាថា នៅក្នុងភូមិមួយ មានលោកតាម្នាក់មានដុះពុកមាត់និងពុកចង្កាស្រមូម នៅផ្ទះជិតគ្នានោះដែរគ្រួសារមួយមានទារកតូចម្នាក់ពូកែង៉ក់ង៉រ និងយំច្រើនពេលដែលម្ដាយរបស់វានិយាយបន្លាចថា "បើមិនឈប់យំម៉ែនឹងឲ្យលោកតាពុកមាត់វែងមកក្រៀវហើយ" ក្មេងនោះភ័យខ្លាច ហើយក៏ឈប់យំទៅ ប៉ុន្តែដល់ពេលទារកនោះធំឡើង ទាំងខ្លួនរបស់គេក៏មានពុកមាត់ដែរ គេក៏លែងខ្លាចលោកតានោះ សូម្បីអ្នកណាបន្លាចទៀតក៏មិនខ្លាចដែរ ព្រោះបានដឹងច្បាស់ថា ការដុះពុកមាត់គឺជារឿងធម្មតា ។

ម្យ៉ាងទៀត ការដែលព្រះមានព្រះភាគទ្រង់បង្គាប់ឲ្យយើងគ្រប់គ្នារលឹកដល់សេចក្ដីស្លាប់នេះ ប្រយោជន៍ដើម្បី

កុំឲ្យយើងមានការស្រើនរនេងក្នុងជីវិត ដែលហៅថា **ជីវិតមនោ** និងឲ្យសត្វលោកត្រូវតែបំពេញសេចក្ដីល្អឲ្យហើយ ព្រោះថា **ជីវិតមិនទៀង ប៉ុន្តែសេចក្ដីស្លាប់ទៀង** ដូចដែលព្រះអង្គទ្រង់ត្រាស់សម្ដែងទុកក្នុងគម្ពីរ សុត្តន្តបិដក មជ្ឈិម-និកាយ ឧបរិបណ្ណាសកៈ វិភង្គវគ្គ ភទ្ទេកវត្តសូត្រថា

**អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ**
**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។**

ការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថាសេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ។

៤. **សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ** អាត្មាអញត្រូវតែព្រាត់ប្រាស និរាសចាកសត្វនិង

សង្ខារជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខានឡើយ។

សត្វលោកតែងភ័យខ្លាចចំពោះសត្វនិងសង្ខារ ដែលមិនជាទីស្រឡាញ់ពេញចិត្ត ហើយប្រាថ្នាចង់បាននូវសត្វនិងសង្ខារដែលជាទីស្រឡាញ់ពេញចិត្ត តែគេមិនបានដឹងទាល់តែសោះថា របស់ដែលជាទីស្រឡាញ់នោះហើយ គឺជាប្រភពនៃសេចក្តីទុក្ខកង្វល់។

រឿងរ៉ាវក្នុងជីវិត មិនមែនចេះតែសម្រេចទៅតាមការប្រាថ្នាទេ ប៉ុន្តែរបស់ទាំងអស់តែងជាគូនឹងគ្នាគឺ **បាន ជាគូនឹងការបាត់បង់, ជួប ជាគូនឹងការព្រាត់ប្រាសជាដើម** ព្រោះជារបស់ដែលមានសភាពប្រែប្រួលទៅ ដូចជាខ្សែទឹកក្នុងស៊ីងតែងហូរពីទីខ្ពស់ទៅកាន់ទីទាបជានិច្ចដូច្នោះ។

កាលបើយើងមិនបានពិចារណា អំពីបម្រែបម្រួលនៃសង្ខារធម៌ឲ្យបានរឿយៗទេ ពេលដែលរបស់ជាទីស្រឡាញ់ព្រាត់ប្រាសទៅ លទ្ធផលជាក់ស្តែងគឺសេចក្តីសោកសង្រេង

យ៉ាងគួរឲ្យអាណិត ព្រោះហេតុដូច្នោះទើបព្រះមានព្រះភាគ ជាម្ចាស់ទ្រង់ត្រាស់សម្តែងក្នុងគម្ពីរ ខុទ្ទកនិកាយ ធម្មបទ-គាថា បិយវគ្គ ថា

**បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ**

**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យ

កើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះ

ចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក

ក៏លែងមាន ភ័យនឹងមានមកពីណា ។

របស់របរជុំវិញជីវិតនេះ ពេលដែលបាត់បង់ទៅ បើស្រឡាញ់ខ្លាំង ទុក្ខក៏ខ្លាំង ស្រឡាញ់តិចទុក្ខក៏តិច ព្រោះហេតុដូច្នោះ ទើបព្រះពុទ្ធអង្គប្រៀនប្រដៅមិនឲ្យសត្វលោកប្រកាន់មាំក្នុងរបស់អ្វីមួយ ឲ្យច្រើនកើនពេក មិនឲ្យស្រឡាញ់រហូតវង្វេង មិនឲ្យតាំងសេចក្តីសង្ឃឹមពិតស្អិត

ជាប់ក្នុងរបស់ណាមួយឡើយ ព្រោះកាលខុសបំណងក៏នាំឲ្យកើតទុក្ខកង្វល់ៗ

និយាយយ៉ាងនេះ មិនមែនឲ្យយើងលះបង់សេចក្ដីសង្ឃឹមក្នុងជីវិតនោះទេ យើងក៏អាចមានសេចក្ដីសង្ឃឹមបានដែរ ប៉ុន្តែត្រូវត្រៀមខ្លួនឲ្យសព្វគ្រប់ ទុកសម្រាប់តទល់នឹងផលទាំងពីរយ៉ាងរបស់វា **គឺសេចក្ដីសមបំណង និងសេចក្ដីខុសបំណង**ៗ

ការងារគ្រប់យ៉ាងមានគតិជាពីរ គឺបានសម្រេចនិងរលំរលាយ, កីឡាគ្រប់យ៉ាងមានផលពីរ **គឺចាញ់និងឈ្នះ** បើស្រឡាញ់ការលេងកីឡា យើងត្រូវព្រមទទួលផលទាំងពីរយ៉ាងដូច្នោះដែរ មិនមានមនុស្សណាម្នាក់ បានទទួលតែរសជាតិផ្អែមល្ហែមតែម្យ៉ាង ឬរសជាតិជូរចត់តែម្យ៉ាង រហូតមួយជាតិទេ ព្រោះហេតុដូច្នោះ គ្រប់គ្នាត្រូវតែត្រៀមខ្លួនទុកជាមុន បើមិនដូច្នោះទេ ពិតជានឹងក្រឡុកចិត្តមិនខានៗ

អ្នកដែលបានពិចារណាតាមមាតិកាធម៌នេះ ឈ្មោះថា ជាអ្នកបានត្រៀមខ្លួនទុកជាមុន គេរមែងផញញឹមជានិច្ច ទាំងគ្រាបាន ទាំងគ្រាបង់ ទាំងគ្រាសមបំណង ទាំងគ្រាខុសបំណង ជីវិតរបស់គេនឹងរឹងប៉ុងឡើងជាលំដាប់ រហូតដល់មានខ្លួនឯងជាទីពឹងពិតប្រាកដ ៗ

៥. កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ. អាត្មាអញនឹងធ្វើនូវកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះមិនខាន ៗ

ពាក្យថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ នៅតែមានលក្ខណៈត្រឹមត្រូវ និងអាចពិសោធបានគ្រប់ពេល ៗ

**កម្ម** គឺជាការងារដែលសត្វលោកត្រូវប្រព្រឹត្តធ្វើទៅតាមផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត **រីឯផល** គឺជាលទ្ធផលដែលសម្រេចបានព្រោះអាស្រ័យកម្មគឺការងារនុ៎ះឯង។

ការងារល្អ នាំឲ្យជីវិតស្រស់បស់ទាំងផ្នែកផ្លូវកាយ ទាំងផ្នែកផ្លូវចិត្ត ព្រោះត្បិតមិនបានក្តៅក្រហាយស្តាយក្រោយ បើបច្ចុប្បន្នបានល្អហើយ ទៅអនាគតក៏កាន់តែល្អឡើងជាលំដាប់។

ការងារល្អ គឺប្រសូតចេញអំពីគំនិតល្អ ដូចព្រះមានព្រះភាគទ្រង់ត្រាស់សម្តែង ក្នុងគម្ពីរខុទ្ទកនិកាយ គាថាព្រះធម្មបទ ថា

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**

**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**

**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ។

ស្រមោល គឺជារបស់ម្យ៉ាងដែលតែងតែអន្ទោលទៅតាមសត្វលោកគ្រប់ឥរិយាបថទាំងបួន យ៉ាងណាមិញ សេចក្តីសុខដែលជាផលរបស់បុណ្យ ក៏រមែងមិនលះបង់នូវសត្វលោកដូច្នោះដែរ ប៉ុន្តែសេចក្តីសុខក្នុងជីវិត មិនមែនបានមកដោយគ្រាន់តែការប្រាថ្នា ហើយខ្វះខាតសេចក្តីព្យាយាមឡើយ បើខ្វះខាតហេតុនៃសេចក្តីសុខហើយ ទោះបីប្រាថ្នាយ៉ាងណាក៏មិនបាន ឧបមាដូចជាការដាំដំណាំ បើមិនមានការថែទាំ ផលពិតជាមិនបរិបូណ៌ តែបើថែទាំដោយ

ល្អហើយ ផលពិតជាសម្រេចបានតាមបំណងមិនខាន ដូច្នេះ "បើចង់បានផ្លែ ត្រូវតែខំថែគល់ កោតផលនឹងផ្តល់តាមប្រាថ្នា"។

ដូចគ្នានេះដែរ ព្រះមានព្រះភាគទ្រង់ត្រាស់ជាស់តឿនក្នុងព្រះធម្មបទ ថា

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**

**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរស(ស្ត្រី) គប្បីធ្វើនូវបុណ្យ គប្បីធ្វើនូវបុណ្យនុ៎ះឲ្យរឿយៗ គប្បីធ្វើនូវសេចក្តីពេញចិត្តក្នុងបុណ្យនុ៎ះ (ព្រោះថា) កិរិយាសន្សំនូវបុណ្យរមែងនាំមកនូវសេចក្តីសុខ។

ឯការធ្វើអាក្រក់ នាំឲ្យជីវិតអួអាប់ទាំងផ្នែកផ្លូវកាយ ទាំងផ្នែកផ្លូវចិត្ត ព្រោះត្បិតអំពើអាក្រក់នុ៎ះ តែងញាំងបុគ្គលនោះឲ្យក្តៅក្រហាយរឿយៗ បើបចុប្បន្នអាក្រក់ហើយ

ទៅអនាគត ផលអាក្រក់ប្រាកដជានឹងកើតឡើងដោយគេច

មិនផុត។

ការងារអាក្រក់ គឺប្រសូតចេញអំពីគំនិតអាក្រក់ ដូច

ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែង ក្នុងគម្ពីរខុទ្ទកនិកាយ

គាថាព្រះធម្មបទថា

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**

**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**

**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្ត

ប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត

បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយពោល

ក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ

រមែង ជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិល

តាមដានជើងគោដែលកំពុងអូសទៅ។

គោដែលចូលក្នុងទឹមហើយ តែងដល់នូវការលំបាក ប្រាណ មិនងាយនឹងបានសម្រាកឡើយ បើខំស្ទុះទៅមុខ ទឹមនឹងសង្កត់ក បើចង់ឈប់ នាយសារថីនឹងចាក់ដោយ ជន្លួញ បើឈានថយក្រោយ កង់រថនឹងសង្កត់កែងជើង ដូច្នេះមានតែទ្រាំដើរទៅទាំងការទៀយហត់ៗ

នេះជាការសម្ដែងថា សត្វលោកទាំងអស់ដែលបាន កើតមកក្នុងលោកនេះ សុទ្ធតែនៅក្នុងទឹមរបស់នាយសារថី គឺកម្មដែលខ្លួនបានធ្វើដូចៗគ្នា បើធ្វើល្អ សេចក្ដីសុខក៏នឹង កើតឡើងជារឿយៗ បើធ្វើអាក្រក់ សេចក្ដីទុក្ខក៏នឹងកើត ឡើង ទោះបីខំប្រឹងប្រើវិធីមន្តអាគម រំដោះគ្រោះ ពាក់ខ្សែ យ័ន្តកថា ឬថារត់ទៅពួននៅទីណា ក៏មិនរួចខ្លួនឡើយ ព្រោះ ហេតុនោះទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងទុកក្នុង គាថាព្រះធម្មបទ ថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**

**ន បព្វតានំ វិវរំ បវិស្ស**

**ន វិជ្ជតី សោ ជគតិប្បទេសោ**

**យត្ថដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។**

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅពួជ័អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយគប្បីរួចចាកបាបកម្មបាននោះមិនដែលមានឡើយ។

ម្យ៉ាងទៀត បើនិយាយពីកម្លាំង ព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងបាទនៃព្រះគាថាធម្មបទថា "**នត្ថិ កម្មំ សមំ ពលំ** មិនមានកម្លាំងអ្វីស្មើដោយកម្លាំងកម្មឡើយ" ។

ដូច្នេះ ក្នុងនាមជាពុទ្ធបរិស័ទ ដែលជាអ្នកជ្រកកោនក្នុងសាសនានៃព្រះជិនស្រី គួរតែបានយល់ដឹងអំពីកម្មនិងផលឲ្យបានច្បាស់លាស់ កុំរវល់តែភ្ញាក់ផ្អើលទៅជឿរឿង

អបិយជំនឿផ្សេងៗ ដែលនាំឲ្យកាន់តែអាប់ឱនប្រាជ្ញាស្មារតីកាន់តែខ្លាំងឡើងៗនោះឡើយ គួរតែបែងចែកពេលវេលាខ្លះសម្រាប់សិក្សាស្វែងយល់នូវព្រះធម៌ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីឲ្យបានរឿយៗ មិនយូរប៉ុន្មានពុទ្ធបរិស័ទនឹងអាចមានលំនឹងផ្នែកប្រាជ្ញាស្មារតី អាចជ្រើសរើសផ្លូវដ៏ប្រសើរសម្រាប់ជីវិតមិនខាន។

| | |
|---|---|
| ជីវិតកើតមកតែងប្តូរផ្លាស់ | ក្មេងក្លាយជាចាស់អស់យុវវ័យ |
| មិនស្លាប់ពីក្មេងគង់ដល់ថ្ងៃ | ទៅជាតាយាយជាក់មិនខាន។ |
| បន្ទាប់ពីចាស់មានថ្ងៃមួយ | ចិន្តាទុក្ខព្រួយរញ្ជួយប្រាណ |
| គឺថ្ងៃមច្ចុទាញចាកឋាន | រុញច្រានសត្វលោកឱ្យមរណា។ |
| គ្រាកាលរស់នៅក៏អភ័ព្វ | ព្រោះត្បិតស្អិតជាប់ក្នុងកាមា |
| ពេលវិនាសទ្រព្យគាប់ចិន្តា | ក្នុងទ្រូងខ្លោចផ្សាឥតស្រាកស្រាន្ត។ |
| បើបានសិក្សាពីរឿងកម្ម | ដែលមានប្រចាំក្នុងសន្តាន |
| ក្តីទុក្ខនឹងប្រែជាក្សេមក្សាន្ត | ព្រោះហេតុពីបានយល់រឿងពិត។ |

ភិក្ខុវជិរប្បញ្ញោ **ស.ស.ខ**

# ៥-ជីវិតស្ទុកលោក

ព្រះសម្មាសម្ពុទ្ធ បានប្រៀបធៀបសាកសពទៅនឹងអង្កត់ឧស ដែលនៅក្នុងព្រៃ ដោយសេចក្តីថា អង្កត់ឧសជាវត្ថុមិនមានប្រយោជន៍ តែបើគេត្រូវការដោយប្រការណាមួយ គង់អាចយកមកប្រើឲ្យបានសម្រេចប្រយោជន៍ខ្លះមិនខាន ឯសាកសពមនុស្សយើង មិនត្រឹមតែមិនមានប្រយោជន៍ប៉ុណ្ណោះទេ ថែមទាំងមានក្លិនអសោចិ៍ទៀតផង។

សាកសពអាក្រក់មែនហើយ តែមិនអាក្រក់ដូចមនុស្សរស់ ដែលប្រព្រឹត្តអាក្រក់ទេ ព្រោះសាកសពអាក្រក់តែរូបនិងក្លិនមិនល្អប៉ុណ្ណោះ បើគេយកទៅកប់ឬដុតហើយភាពអាក្រក់និងក្លិនមិនល្អក៏លែងមានដែរ ចំណែកមនុស្សរស់ដែលប្រព្រឹត្តអាក្រក់ គឺអាក្រក់ជាងសាកសពដោយពិតព្រោះបៀតបៀនទាំងខ្លួនឯងនិងអ្នកដទៃ។

ម្យ៉ាងទៀត សាកសពមនុស្សស្លាប់ ជារបស់គ្មានប្រយោជន៍ ព្រោះមិនអាចបំពេញកិច្ចការងារផ្សេងៗ ដូចជា

ធ្វើការងារអាជីវកម្ម ការងារសង្គ្រោះអ្នកដទៃ ការធ្វើទាន ការរក្សាសីល ការទូន្មានអប់រំចិត្តសន្តាន ដោយការស្តាប់ធម៌ជាដើមបានឡើយ ចំណែកមនុស្សដែលរស់នៅ តែមិនបានប្រើប្រាស់ជីវិតប្រព្រឹត្តធ្វើនូវប្រយោជន៍ ដល់ខ្លួនឯងនិងអ្នកដទៃ ដោយផ្តើមសាងគុណធម៌ប្រចាំចិត្តសន្តានទេ ពិតជាបានឈ្មោះថា ជាមនុស្សដែលកើតមកដើម្បីចង្អៀតលោកមិនខាន ត្បិតគ្មានបាននាំមកនូវប្រយោជន៍ដល់ពិភពលោកនេះសោះ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងបាទនៃព្រះគាថាធម្មបទ ថា "**ន សិយា លោកវឌ្ឍនោ** មិនគប្បីធ្វើជាមនុស្សរុំកលោកឡើយ"។

| | |
|---|---|
| សាកសពអាក្រក់ៗមែនហើយ | នៅឡើយគង់ចាញ់ជនទ្រុស្តសីលា |
| សាកសពគេខ្លាចតែព្រៃប៉ាធា | ខ្លាចមនុស្សបួស្សាទាំងរាជធានី។ |
| ជីវិតកើតមកដើម្បីប្រយោជន៍ | កុំអន់ជាងខ្មោចទាំងមានជីវី |
| កើតមកកុំឱ្យចង្អៀតធរណី | ត្រាប់ព្រះមុនីបណ្តុះនិស្ស័យ។ |

ភិក្ខុវជិរប្បញ្ញោ **ស.ស.៩**

# ៦-ជីវិតរន្ធការ

កាពងងឹតអន្ធការ មិនមែនជារបស់ដែលអ្នកណាម្នាក់បង្កើតមកទេ ជារបស់ដែលមានជាធម្មតាប្រចាំលោកនេះ ឲ្យតែទីណាខ្វះពន្លឺ ងងឹតក៏នឹងមាននៅក្នុងទីនោះ។

អវិជ្ជា ក៏ជាធម្មជាតិម្យ៉ាង កើតអាស្រ័យនឹងជីវិតសត្វលោកគ្រប់គ្នា វៀរលែងតែបុគ្គលដែលបានសម្រេចជាព្រះអរហន្ត។

តាមន័យនៃបដិច្ចសមុប្បាទសម្តែងថា អវិជ្ជា គឺជាមេនៃសង្ខារធម៌ទាំងឡាយ បើនិយាយឲ្យងាយស្តាប់ អវិជ្ជា គឺជាមេនាំអាទិ៍ឲ្យមានតួជីវិតនេះឯង។

អវិជ្ជា ដែលជាស្បែងងឹតនៃជីវិតមាន ៨ យ៉ាងគឺ

**១-ទុក្ខេ អញ្ញាណំ** មិនដឹងក្នុងសេចក្តីទុក្ខ គឺមិនដឹងក្នុងទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើម ដែលជាទុក្ខសច្ចៈ។

២-ទុក្ខសមុទយេ អញ្ញាណំ មិនដឹងនូវធម៌ដែលជាហេតុនាំឲ្យកើតទុក្ខ គឺមិនដឹងនូវតណ្ហា សេចក្ដីប្រាថ្នាគ្រប់យ៉ាង ដែលជាទុក្ខសមុទយសច្ចៈ។

៣-ទុក្ខនិរោធេ អញ្ញាណំ មិនដឹងនូវព្រះនិព្វានជាទីរំលត់នូវសេចក្ដីទុក្ខ ដែលជានិរោធសច្ចៈ។

៤-ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ មិនដឹងនូវផ្លូវជាទីចូលទៅរំលត់នូវសេចក្ដីទុក្ខ ដែលជាមគ្គសច្ចៈ។

៥-បុព្វន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធ អាយតនៈធាតុ ដែលជាអតីត គឺមិនដឹងនូវជាតិកំណើត ដែលធ្លាប់កើតក្នុងជាតិមុនៗ។

៦-អបរន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធអាយតនៈ ធាតុ ដែលជាអនាគត គឺមិនដឹងនូវជាតិកំណើតដែលនឹងកើតតទៅក្នុងជាតិខាងមុខៗទៀត។

៧-បុព្វន្តាបរន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធអាយតនៈ ធាតុ ទាំងក្នុងអតីត ទាំងក្នុងអនាគត។

៨-ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ សេចក្តីមិនដឹងក្នុងនាមរូប ដែលកើតឡើងដោយអាស្រ័យហេតុបច្ច័យ តាមន័យក្នុងបដិច្ចសមុប្បាទ។

ធម៌ដែលលើកមកសំដែងនេះ មានជម្រៅណាស់ ទាល់តែស្តាប់ និងសិក្សាស្រាវជ្រាវច្រើនទើបមិនមានការយល់ខុស បើនិយាយយកន័យដោយខ្លី សំដៅយកអវិជ្ជា ដែលមិនដឹងក្នុងលក្ខណៈ ៣ យ៉ាងគឺ

១-មិនដឹងថា ជីវិតគឺជាអ្វី

២-មិនដឹងហេតុនាំឲ្យកើតជីវិត

៣-មិនដឹងថា ជីវិតគឺជាផលរបស់ហេតុ។

អវិជ្ជាទាំងនេះ មិនមែនមានសម្រាប់តែអ្នកមិនកាន់សាសនា ឬសម្រាប់តែអ្នកកាន់សាសនាផ្សេងៗទេ សូម្បីតែអ្នកកាន់ព្រះពុទ្ធសាសនាក៏ដោយ ដរាបណានៅក្នុងភាពជាបុថុជ្ជន តែងតែមានគ្រប់គ្នាទាំងអស់ ប្លែកគ្នាត្រង់ថា

បើបុថុជ្ជនទុំះ បានអាស្រ័យនឹងធម៌របស់ព្រះមានព្រះភាគច្រើន អវិជ្ជាក៏មិនសូវគ្របសង្កត់ខ្លាំង ប្រសិនបើមិនបានយកធម៌របស់ព្រះមានព្រះភាគជាទីតាំងទេ អវិជ្ជាក៏គ្របសង្កត់ខ្លាំងតាមលំដាប់ រហូតធ្វើឲ្យអ្នកទុំះជឿរឿងមង្គលភ្ញាក់ផ្អើលផ្សេងៗ មានការបន់ស្រន់ ស្រោចទឹក រំដោះគ្រោះជាដើម ដែលជាជំនឿច្រេង ហើយផុយគ្នាស្រឡះអំពីធម៌របស់ព្រះសម្មាសម្ពុទ្ធ។

ជីវិតដែលកើតមកនេះ គឺងងឹតស្រាប់ទៅហើយ បើមាននូវសេចក្ដីប្រមាទធ្វេសប្រហែសបន្ថែមទៀត តើជីវិតនឹងក្លាយទៅជាយ៉ាងណា!

ព្រោះតែសត្វលោកស្ទើរតែទាំងអស់ មានជីវិតរស់នៅក្នុងភាពអន្ធការយ៉ាងនេះ ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែង ក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា លោកវគ្គ ថា

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**

**សត្តវណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ច-លក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ដូច្នោះ ។

| | | |
|---|---|---|
| មានជីវិត | ឥតគំនិត | គិតពិចារណ៍ |
| មិនឧស្សាហ៍ | ស្រវាចាប់ | ស្តាប់ធម្មា |
| មិនដើរតាម | ស្នាមព្រះបាទ | ព្រះភគវា |
| មច្ចុមារ | រាគំនិត | ជិតរហូត។ |

ភិក្ខុវជិរប្បញ្ញោ ស.ស.ខ

# ៧-គ្រឿងជីវិត

ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ និងវិញ្ញាណ ដែលដឹងច្បាស់នូវអារម្មណ៍ទាំងនោះ ព្រមទាំងវេទនា ទាំងឡាយដែលសោយតាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទ្វារចិត្ត គឺជាតួជីវិតដែលជារបស់ក្តៅ។

នៅក្នុងអាទិត្តបរិយាយសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងអំពីរបស់ក្តៅ មាន ២៤ ចំណុចធំៗគឺ

១-ភ្នែក ជារបស់ក្តៅ

២-រូប គឺពណ៌ ជារបស់ក្តៅ

៣-ចក្ខុវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវរូបនោះ ជារបស់ក្តៅ

៤-ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី

មិនមែនទុក្ខមិនមែនសុខក្តី កើត

ឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ

ជារបស់ក្តៅ។

៥-ត្រចៀក ជារបស់ក្តៅ

៦-សម្លេង ជារបស់ក្តៅ

៧-សោតវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវ

សម្លេងនោះ ជារបស់ក្តៅ

៨-ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជា

ទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើត

ឡើងព្រោះសោតសម្ផស្សជាបច្ច័យ

ជារបស់ក្តៅ។

៩-ច្រមុះ ជារបស់ក្តៅ

១០-ក្លិន ជារបស់ក្តៅ

១១-ឃានវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវក្លិននោះ

ជារបស់ក្តៅ

១២-ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្សជាបច្ច័យ ជារបស់ក្តៅ។

១៣-អណ្តាត ជារបស់ក្តៅ

១៤-រសទាំងឡាយ ជារបស់ក្តៅ

១៥-ជិវ្ហាវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវរសនោះ ជារបស់ក្តៅ

១៦-ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ជារបស់ក្តៅ។

១៧. កាយ ជារបស់ក្តៅ

១៨. ផោដ្ឋព្វៈ គឺសភាព ក្តៅ ត្រជាក់ ទន់ រឹង កម្រើក ញ័រ ជារបស់ក្តៅ

១៩. កាយវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវផោដ្ឋព្វៈ

នោះ ជារបស់ក្តៅ

២០. ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជា

ទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើត

ឡើងព្រោះកាយសម្ផស្សជាបច្ច័យ

ជារបស់ក្តៅ។

២១. ចិត្ត ជារបស់ក្តៅ

១២. ធម៌ទាំងឡាយ គឺអារម្មណ៍ទាំងឡាយ ដែលដឹង

តាមផ្លូវចិត្ត ជារបស់ក្តៅ

២៣. មនោវិញ្ញាណ គឺវិញ្ញាណដែលដឹងច្បាស់នូវធម៌

ទាំងឡាយនោះ ជារបស់ក្តៅ

២៤. ការសោយនូវអារម្មណ៍ គឺវេទនាជាសុខក្តី ជា

ទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី

កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ

ជារបស់ក្ដៅ។

ធម៌ទាំងឡាយនេះ មិនមែនក្ដៅឯងៗទេ គឺក្ដៅព្រោះបច្ច័យ ដូច្នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់បញ្ជាក់បន្ថែមថា

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ ។**

តថាគតពោលថា ក្ដៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្ដៅដោយសេចក្ដីកើត ដោយសេចក្ដីចាស់គ្រាំគ្រា និងសេចក្ដីស្លាប់ ក្ដៅដោយសេចក្ដីសោក ដោយសេចក្ដីខ្សឹកខ្សួល ដោយ

សេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។

នាពេលបច្ចុប្បន្ននេះ បើទុកជាមិនមានអ្នកណាប្រាប់ក៏យើងអាចដឹងបានថា សត្វលោកកំពុងតែរស់នៅក្នុងកម្តៅ ហើយកម្តៅនេះ កាន់តែមានកំណើនកើនឡើងជាលំដាប់។

សភាពទាំងអស់នេះ ក៏ព្រោះតែភ្លើងគឺកិលេស មានរាគៈ ជាដើម ដែលអាស្រ័យនៅក្នុងចិត្តរបស់សត្វលោក កាន់តែមានចំហេះខ្លាំងឡើងៗ ដោយហេតុថា សត្វលោកកាន់តែខ្វាត មានល្បិចកលពិសពុល ក្នុងការផ្គុំភ្លើងតណ្ហាឲ្យកាន់តែមានកម្លាំងខ្លាំងឡើងៗ ជាលំដាប់។ សត្វលោករឹតតែគ្មានជំនឿ គ្មានប្រកាន់យកថា ការពន្លត់ភ្លើងរាគៈ ទោសៈ មោហៈ គឺជាចំណុចត្រជាក់ដ៏កំពូលនោះទេ ផ្ទុយមកវិញ គេច្រើនតែស្វែងរកសេចក្តីសប្បាយរីករាយលើបញ្ចកាមគុណ ដែលជាការពង្រីកភ្នក់ភ្លើងជីវិតឲ្យកាន់តែធំ

ដោយគំនិតបញ្ឆេះច្រើនជាងគំនិតពន្លត់ៗ

សកលលោក បានក្លាយទៅជាលោកដែលមានកម្តៅ ទាំងមនុស្ស ទាំងសត្វ ទាំងសកលធាតុ ក៏ព្រោះតែមនុស្ស ក្នុងពិភពលោក នាំគ្នាស្វាបអង្អែលនូវបញ្ចកាមគុណ នាំគ្នា បម្រើសេចក្តីសប្បាយបោកប្រាស់ ប្រកបដោយចិត្ត ពោរពេញទៅដោយរាគៈ ទោសៈ មោហៈ លើសពីសម័យ មុន ១ ជា ១០ ឬ ១ ជា ២០ ក៏អាចថាបានៗ

សព្វថ្ងៃនេះ មនុស្សបាននាំគ្នាពពាក់ពពូនជំពាក់ជំពិន ទៅលើអំពើដុតកម្តៅខ្លួនឯង គឺនាំគ្នាជូរ នាំគ្នាជូរចត់ក្នុងជីវិត របស់ខ្លួន នាំគ្នាបង្កើនកិលេសរបស់ខ្លួន ខ្លះទៀតប្រាថ្នាលើក ខ្លួនរបស់គេជាម្ចាស់ពិភពលោកៗ

ជាងនេះទៅទៀត គំនិតរបស់សត្វលោកម្នាក់ៗ តែង មានការប្រកាន់យកនូវរបស់មិនទៀង ជាទុក្ខ ជាអនត្តា ថាជារបស់ទៀង ជាសុខ ជាអត្តាៗ ប៉ុន្តែការប្រកាន់ និង

គំហើញទាំងនេះ លទ្ធផលចុងក្រោយ គឺសំណើចលាយទំនួញ សំអប់លាយសម្លាញ់ សម្លូតលាយកំណាចជាដើម ដែលផ្លាស់ប្តូរគ្នាទៅវិញទៅមកឥតឈប់ឈរ ស្ថិតក្រោមលក្ខណៈដុតបំផ្លាញជីវិតខ្លួនឯងដោយវិធីផ្សេងៗ យ៉ាងគួរឲ្យសង្វេគខ្លោចផ្សាដោយគ្មានដឹងខ្លួនឡើយៗ

ក្នុងពិភពលោកនេះ មិនមានទីណាមួយ ដែលមានសភាពសុខត្រជាក់ពិតប្រាកដសម្រាប់សត្វលោក ដែលនៅមានកិលេសឡើយ ទោះបីសត្វលោកខំគេចពីកន្លែងមួយទៅកន្លែងមួយ ពីប្រទេសមួយទៅប្រទេសមួយយ៉ាងណាក៏ដោយ ឲ្យតែនៅមានកិលេស ជីវិតនៅតែក្តៅជានិច្ចៗ

ពេលភ្លើងឆេះផ្ទះ វិធីដែលសមស្រប មិនមែនត្រូវយកឧសទៅដាក់បន្ថែម ឬលើកផ្ទះរត់ឡើយ គឺត្រូវតែយកទឹកទៅពន្លត់ភ្លើងដែលកំពុងឆេះទ្រុះឯង យ៉ាងណាមិញ ជីវិតដែលក្តៅគគុកនេះ ក៏មិនខុសអំពីផ្ទះដែលភ្លើងកំពុងតែ

ចេះដែរ សេចក្តីឧបមានោះ យ៉ាងនេះគឺ

-ជីវិតដែលមានកិលេស ដូចជាផ្ទះដែលភ្លើង

កំពុងឆេះ

-ការស្វែងរកកាមគុណ គឺសេចក្តីសប្បាយមកបន្ទប់

ដូចជាការដាក់ឧសបន្ថែម

-ការរត់គេចពីបញ្ហា ដូចជាការលើកផ្ទះដែលភ្លើង

កំពុងឆេះរត់ទៅ

-ការសិក្សាធម៌ចម្រើនប្រាជ្ញា ដូចជាការយកទឹក

ទៅពន្លត់ភ្លើង

ដូច្នេះ ជីវិតដែលត្រូវភ្លើងឆេះ គឺមានចំពោះតែជីវិតដែលនៅមានកិលេសជាគ្រឿងដុតពេល បើកិលេសមិនមានហើយ ភាពក្តៅក្រហាយនៃជីវិតរមែងមិនមាន មានតែសភាពត្រជាក់ ទាំងពេលដែលនៅមានជីវិត និងពេលដែលលាចាកលោកនេះទៅៗ

*សូមមនុស្សគ្រប់គ្នា បានសិក្សាអំពីវិធីពន្លត់ភ្លើងជីវិត*

## ៨៥ *សូមកុំឆ្លាតតែខាងបញ្ឆោះ។*

| | |
|---|---|
| អគ្គីជាឈ្មោះនៃកិលេស | ប្រជុំចាក់ស្រែះចិត្តសន្តាន |
| ជាភ្លើងកំណាចកាចសាមាន្យ | រំខានសត្វលោកគ្មានយោគយល់។ |
| លោភៈទាក់ចិត្តឱ្យជិតជាប់ | មិនងាយនឹងផ្តាប់ឱ្យស្កប់ស្កល់ |
| ទោះបានសម្បត្តិទាំងសកល | ក៏មិនដែលស្គាល់ការគ្រប់គ្រាន់។ |
| ទោសៈចាក់ចិត្តឱ្យក្តៅផ្សា | រំជួលឱរាឆ្វេឆ្វាស្លន់ |
| ជូនក្រោធជូនខ្លាចអាជ្ញាទណ្ឌ | ជូនភ័យបន់ស្រន់សុំសុខា។ |
| មោហៈអន្ទាក់ដាក់ជីវិត | ជាផ្ទាំងងងឹតបាំងបញ្ញា |
| បង្កើតសត្វលោកក្នុងសង្សារ | រួចហើយប្រហារសង្ខារបង់។ |
| បើបានស្តាប់ធម៌អប់រំចិត្ត | ស្មោះស្ម័គ្រប្រព្រឹត្តតាមពុទ្ធអង្គ |
| ដុសខាត់កាយចិត្តឱ្យផូរផង់ | ពិតអាចស្រោចស្រង់អង្គអាត្មា។ |

ភិក្ខុវជិរប្បញ្ញា ស.ស.៩

## ៨-ជីវិតនិងឧបសគ្គ

តើយើងត្រូវឆ្លងកាត់ នូវឧបសគ្គក្នុងជីវិតបានដោយវិធីណា?

មនុស្សយើង សុទ្ធតែមានការពិសោធន៍ផ្សេងៗអំពីគ្នា តែដោយច្រើន អ្នកដែលអាចឆ្លងកាត់នូវព្យុះជីវិតបានដោយជោគជ័យ គឺអ្នកដែលមានការយល់ដឹងច្រើន រួមផ្សំជាមួយនឹងសេចក្ដីអត់ធន់ព្យាយាមផងៗ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្ដែងនូវឥទ្ធិបាទធម៌ គឺធម៌ដែលជាហេតុញ៉ាំងប្រយោជន៍ឲ្យសម្រេចមាន៤យ៉ាងគឺ

**១-ឆន្ទៈ:** សេចក្ដីបំណងក្នុងកិច្ចការងារនោះ ចង់ឲ្យការងារនោះបានសម្រេចតាមប្រាថ្នាៗ

ការប្រាថ្នាដើម្បីនឹងធ្វើនូវកិច្ចការណាមួយ មិនមែនទាល់តែមានលោភៈ ឬតណ្ហាទើបធ្វើបាននោះទេ ដូចបំណង

ក្នុងការធ្វើទាន បំណងក្នុងការរក្សាសីល បំណងក្នុងការប្រកបមុខរបរដែលប្រាសចាកទោស បំណងប្រកបកិច្ចការឲ្យបានជាប្រយោជន៍ដល់ខ្លួនឯងនិងអ្នកដទៃជាដើម សុទ្ធតែជាបំណងល្អដែលគួរបណ្ដុះតទៅទៀត។

ការងារគ្រប់យ៉ាង មិនចាំបាច់ដល់ទៅការងារធ្ងន់ឬលំបាកធ្វើទេ សូម្បីការងារស្រាលៗ បើខ្វះឆន្ទៈហើយ គឺមិនអាចធ្វើកើតឡើយ។

**២-វីរិយៈ** សេចក្ដីព្យាយាម ក្នុងការបំពេញកិច្ចការនោះៗ ឲ្យបានសម្រេច។

ការងារគ្រប់បែបយ៉ាង បើមិនមានសេចក្ដីព្យាយាមទេ សូម្បីបានមកដល់ដៃហើយក៏ដោយ ក៏អាចបាត់បង់ទៅវិញបានដែរ ហើយជីវិតក៏នឹងដើរថយក្រោយ គ្មានជំហានឈានទៅរកសេចក្ដីចម្រើនរុងរឿង មិនអាចដកខ្លួនចាករណ្ដៅទុក្ខបានឡើយ។

វិរិយៈគឺសេចក្ដីព្យាយាមនេះ អាចកម្ចាត់បង់បាននូវកោសជ្ជៈគឺសេចក្ដីខ្ជិលច្រអូស ៦ យ៉ាងគឺ

ក-ខ្ជិលច្រអូសព្រោះគិតអាងថា ក្ដៅពេក

ខ-ខ្ជិលច្រអូសព្រោះគិតអាងថា ត្រជាក់ពេក

គ-ខ្ជិលច្រអូសព្រោះគិតអាងថា ព្រឹកពេក

ឃ-ខ្ជិលច្រអូសព្រោះគិតអាងថា ល្ងាចពេក

ង-ខ្ជិលច្រអូសព្រោះគិតអាងថា ឃ្លានពេក

ច-ខ្ជិលច្រអូសព្រោះគិតអាងថា ឆ្អែតពេក

មនុស្សកម្ជិល តែងអាងលេស ៦ យ៉ាងនេះឯង ម៉្លោះហើយ ការងាររបស់គេ មិនដែលសម្រេចបានដោយល្អទេ គឺតែងខ្វះមុខខ្វះក្រោយជានិច្ច បើជាអ្នកធ្វើការងារក្នុងក្រសួងឬមន្ទីរនានា តែងត្រូវចៅហ្វាយនាយស្ដីបន្ទោសជារឿយៗ ព្រោះហេតុតែគេទៅធ្វើការមិនទាន់ពេលវេលា រហូតអាចគេបញ្ឈប់ពីការងារក៏សឹងមាន។

សេចក្តីព្យាយាម មិនមែនអាចធ្វើងកាត់បានត្រឹមតែការងារចិញ្ចឹមជីវិតប៉ុណ្ណោះទេ សូម្បីបដិបទាជាដំណើរចេញចាកអំពីសង្សារទុក្ខនេះ ក៏រមែងសម្រេចបានដោយសេចក្តីព្យាយាមដែរ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងអាឡវកសូត្រថា" **វីរិយេន ទុក្ខមច្ចេតិ** សត្វឆ្លងនូវអន្លង់ទុក្ខបាន ដោយសេចក្តីព្យាយាម"។

**៣-ចិត្តៈ** ការយកចិត្តទុកដាក់ក្នុងការងារនោះៗ។

ការងារមួយចំនួន សូម្បីស្ទាត់ជំនាញហើយក៏ដោយ បើខ្វះការផ្ចិតផ្ចង់ ធ្វើដោយប្រថុយប្រថាន ការងារនោះក៏ទៅជាឃើករឃោក យកជាការមិនបាន ដោយហោចទៅសូម្បីការស្តាប់ព្រះធម៌ បើមិនមានសមាធិ មិនមានការតាំងចិត្តស្តាប់ដោយល្អ ប្រាកដជាដូចចាក់ទឹកលើក្បាលទាមិនខាន។

**៤-វីមំសា** គឺបញ្ញាដែលពិចារណាឃើញក្នុងការងារនោះៗ ថា ធ្វើយ៉ាងណាការងារនោះអន់ថយ ធ្វើយ៉ាងណា

ការងារនោះបានរីកចម្រើនៗ

ការងារគ្រប់បែបយ៉ាង មិនមែនសម្រេចបានដោយគ្រាន់តែមានកម្លាំងបាយទេ គឺទាល់តែមានប្រាជ្ញាឆ្លាតវាងវៃផងទើបសម្រេចបានដោយល្អ ដូចបុរាណពោលថា "បេះដប់ពុំស្មើនឹងអ្នកប្រសប់មួយ"ៗ

ធម៌ទាំង ៤ ប្រការនេះ ក្នុងមាតិកានីមួយៗ សុទ្ធតែជាសំណៀនសត្វលោកគ្រប់គ្នា ឲ្យមានការទុកចិត្តលើខ្លួនឯងហើយឲ្យផ្ដើមសាងគុណធម៌ ដោយមិនឲ្យកោតញញើតចំពោះឧបសគ្គនានាក្នុងជីវិតឡើយៗ

ដើម្បីបេះនូវផ្កាឈូកដែលដុះក្នុងស្រះ យើងមិនខានពីការប្រឡាក់ភក់ឡើយ តែពេលដែលយើងបេះបានផ្កាឈូកហើយ យើងនឹងឡើងផុតពីស្រះលាងជម្រះកាយឲ្យស្អាតរួចប្រើប្រាស់ផ្កាឈូកនោះទៅតាមចំណង់ យ៉ាងណាមិញគោលដៅនៃជីវិតគឺសេចក្ដីសុខ ដែលយើងកំពុងតែឈាន

*ទៅរកនោះក៏ដូច្នោះដែរ យើងត្រូវតែអត់ធ្មត់ចំពោះភក់ជ្រាំ គឺឧបសគ្គផ្សេងៗ ដូចជាពាក្យសម្ដីចាក់ដោតបញ្ឈឺចិត្តរបស់ពួកមនុស្សមាត់ដាចជាដើម។*

ផ្កាឈូកតែងដុះក្នុងបឹងភក់ លាយដោយទឹកល្អក់ជាធម្មតា
តែពេលឈូកលូតផុតជលសា ក៏ក្លាយជាផ្កាមានរស្មី។
ក្លិនក៏ក្រអូបរូបក៏ល្អ មានទាំងកេសរត្របកថ្មី
ទុកណាជាភ្លៀងជោកជាំដី ផ្កាឈូករីកថ្មីមិនសើមឡើយ។
រីជាតិជាមនុស្សរស់ក្នុងលោក ជាប់ស្មោកក្នុងភក់ឆ្ងាយពីត្រើយ
លង់ក្នុងកិលេសឥតស្រាកស្បើយ កុំនៅកន្តើយប្រឹងឆាប់រ៉ា។
គួរយកតម្រាប់ផ្កាបទុម បីតថ្កុំជីវជាតិគឺកុសលា
សន្សំកេសរគឺបញ្ញា លូតផុតសង្សារដូចផ្កាឈូក។

ភិក្ខុវជិរប្បញ្ញោ ស.ស.ខ

# ៩.ជីវិតអ្នកបម្រើសម័យ

មនុស្សទាន់សម័យ គាត់ច្រើនត្រូវបានគេនិយាយសំដៅទៅលើមនុស្ស ដែលប្រើប្រាស់នូវរបស់របរទំនើបៗ និងមនុស្សដែលចូលចិត្តដើរលេងកម្សាន្ត ច្រៀងរាំជាដើម ហើយឲ្យតម្លៃទៅលើ អ្នកដែលប្រើប្រាស់របស់របរអន់ ឬថោក និងមិនចូលចិត្តរាំច្រៀងជាដើម ថាជាមនុស្សមិនទាន់សម័យទៅវិញ។

ការប្រើប្រាស់នូវរបស់ដែលទំនើប និងដែលមានតម្លៃច្រើន បើអ្នកប្រើមានចំណេះខ្ពង់ខ្ពស់ និងមានសតិស្មារតីក្នុងការប្រើប្រាស់ឲ្យបានជាប្រយោជន៍ សមទៅនឹងរបស់នោះនេះចាត់ថា ជាការប្រើប្រាស់នូវរបស់សមតាមឋានៈ មិនមែនជាការខ្ជះខ្ជាយឡើយ តែបើប្រើប្រាស់ដោយសេចក្ដីវង្វេងព្រោះគ្រាន់តែដើម្បីភាពហ៊ឺហា និងការបង្អួតដល់ភ្នែកអ្នកដទៃ ការប្រើប្រាស់របៀបនេះ ឈ្មោះថាជាការដុតបំផ្លាញខ្លួនឯងដោយពិតប្រាកដ។

មនុស្សជាយច្រើនគិតថា គេខំស្វែងរកនូវសម្ភារៈទំនើបផ្សេងៗ គឺដើម្បីយកមកបម្រើនូវសេចក្ដីសប្បាយរបស់ខ្លួនឯង តែគេមិនបានដឹងទាល់តែសោះថា ខ្លួនគេកំពុងតែក្លាយជាអ្នកបម្រើនៃសម្ភារៈទាំងអស់នោះ ក្នុងក្របខ័ណ្ឌនៃការបម្រើតណ្ហារបស់ខ្លួនឯងទៅវិញ។

គេសង្កេតឃើញថា ស្ទើរតែគ្រប់ពិធីបុណ្យ តែងមានការច្រៀងរាំយ៉ាងអស់ដៃ ជួនកាលអាចហ៊ានសេពសុរាក្នុងកម្មវិធីបុណ្យនោះក៏សឹងមាន ដោយគិតថា ទង្វើបែបនេះនឹងធ្វើឲ្យខ្លួនគេទៅជាមនុស្សទាន់សម័យ។ តែបើពិចារណាឲ្យជិតដល់ទៅ ទង្វើបែបនេះ មិនមែនជាការងារនៃអ្នកទាន់សម័យទេ ព្រោះគេគ្មានបានទទួលផលប្រយោជន៍អ្វី សូម្បីតិចតួចឡើយ បានតែការងងុយដេក ខាតការងារ បង់ទាំងទ្រព្យសម្បត្តិទៀតផង ឯអ្នកចំណេញ គឺម្ចាស់តន្ត្រី និងអ្នកលក់ដូរឯណោះទេ ដូច្នេះការសប្បាយរបស់គេ ឈ្មោះថាជាការបម្រើសម័យដោយពិត។

ឯអ្នកវិទ្យាសាស្ត្រ ដែលជាអ្នកបង្កើតនូវឧបករណ៍តន្ត្រី ឬគ្រឿងស្រវឹងផ្សេងៗនោះ ខ្លួនគេផ្ទាល់មិនបានវង្វេងដោយឧបករណ៍ទាំងនេះឡើយ គេខិតខំធ្វើយ៉ាងណាបង្កើតសម្ភារៈថ្មីៗទៀត ដើម្បីយកលុយ ពីមនុស្សបម្រើសម័យឲ្យបានច្រើនៗ

ថ្ងៃជាកម្មករធ្វើការហាលក្ដៅ ពេលយប់ក្លាយទៅជាលោកសេដ្ឋី
ជប់លៀងស៊ីផឹកឥតត្រាប្រណី លុះដល់ពេលថ្ងៃកម្មករដដែល។

ភិក្ខុវជិរប្បញ្ញោ ស.ស.៩

## ១០~ជីវិតមាន់ជល់

គេសង្កេតឃើញថា ពេលមាន់ជល់គ្នា តែងមានចាញ់ និងឈ្នះ បើជល់តិចរបួសក៏តិច បើជល់ខ្លាំងរបួសក៏ខ្លាំង ហើយសម្រាប់អ្នកចាញ់ អាចអស់ជីវិតក៏សឹងមាន ឯអ្នកឈ្នះឯណោះវិញ ក៏មិនខានពីការត្រូវរបួសឡើយ ទាំងសងខាងគ្មានបានទទួលអ្វី ក្រៅពីការឈឺចាប់នោះឡើយ ឯផលប្រយោជន៍ត្រូវធ្លាក់ទៅលើម្ចាស់ទាំងអស់ ។

យ៉ាងណាមិញ សត្វលោកទាំងអស់ មិនចំពោះតែមាន់ទេ សូម្បីមនុស្ស បើគិតតែប្រទូសរ៉ាយ ប្រកួតប្រជែងចង់យកឈ្នះអ្នកដទៃដោយគំនិតអាក្រក់ផ្សេងៗ ហើយក៏បៀតបៀនគ្នាទៅ តើមានចំណុចណាដែលគ្រាន់បើជាងមាន់នោះ? សេចក្តីពិត គ្មានបានទទួលអ្វីក្រៅអំពីពៀរវេរា និងការឈឺចាប់ឡើយ ព្រោះគ្រប់គ្នាសុទ្ធតែជាប់នៅក្នុងទ្រុងមច្ចុរាជ សមដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងទុក

ក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា ថា

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**

**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់នូវការឈ្នះនិងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ។

ការចងពៀរវេរានឹងគ្នា គឺប្រសូតចេញពី ឥស្សា (សេចក្ដីប្រណែន) និងមច្ឆរិយៈ (សេចក្ដីកំណាញ់) ។ កាលបានសិក្សាអំពីដំណើរជីវិតហើយ ក៏ឃើញបានថា ក្នុងលោកនេះ មិនមានអ្នកណាម្នាក់គួរឲ្យយើងប្រណែននោះឡើយ ព្រោះក្នុងអ្នកដទៃនោះ ក៏មានសេចក្ដីទុក្ខហើយចង់បានតែសេចក្ដីសុខដូចជាយើងដែរ។

កាលបើយើងប្រណែននឹងអ្នកដទៃ ឈ្មោះថាយើងចង់បានសេចក្ដីសុខពីអ្នកដទៃ ចុះបើអ្នកដទៃនោះមិនមាន

សេចក្តីសុខសម្រាប់ខ្លួនគាត់ផ្ទាល់ផង តើមានសេចក្តីសុខឯណាសម្រាប់ប្រគល់ឲ្យយើង?

សូមមនុស្សគ្រប់គ្នាមានឈ្មោះថា មនុស្សមនុស្សោ ឬថា ជាមនុស្សទេវោ ដោយមានធម៌ប្រចាំចិត្តសន្តាន, សូមកុំធ្វើជាមនុស្សខួរក្បាលមាន់ៗ

> បុគ្គលអ្នកឈ្នះតែងមានពៀរ អ្នកចាញ់គ្រាំគ្រាដេកជាទុក្ខ
> លះការឈ្នះចាញ់ទើបបានសុខ ជាតិនេះជាតិមុខអស់វេរា។
>
> ភិក្ខុវជិរប្បញ្ញោ ស.ស.៩

# ១១.ជីវិតគោចាស់

គ្រប់មនុស្សដែលកើតមកក្នុងលោកនេះ មានទ្រព្យសម្បត្តិយ៉ាងណាក៏ដោយ សុទ្ធតែស្រឡាញ់ការរស់នៅ ទើបបានជាខិតខំបំពេញកិច្ចការងារផ្សេងៗ ទាំងតាមផ្លូវសុចរិតក៏មាន និងតាមផ្លូវទុច្ចរិតក៏មាន ដោយវត្ថុបំណងចង់ឲ្យខ្លួនឯងបានសុខ និងមានសេចក្ដីថ្លៃថ្នូរ មានអ្នកផងរាប់អាន និងទទួលស្គាល់ថាជាមនុស្សគ្រាន់បើ។

ប៉ុន្តែសេចក្ដីសម្រេច ភាពប្រសើរ មិនមែនបានមកដោយការប្រាថ្នា ហើយខ្វះខាតសតិបញ្ញា និងការព្យាយាមនោះទេ បើមិនមានការសិក្សាអប់រំហើយ ទោះបីរស់នៅអស់រយៈឆ្នាំ ឬថាខំបរិភោគនូវអាហារដែលមានរសជាតិដើម្បីបំប៉នសុខភាពយ៉ាងណា ក៏គ្មានតម្លៃអ្វីដែរ គឺចម្រើនតែសាច់ឈាម ហើយសាច់ឈាមនុ៎ះទៀតសោត ទីបំផុតបានត្រឹមតែជាចំណីរបស់ដង្កូវ និងដី ទឹក ភ្លើង ខ្យល់ ទៅវិញ

ដោយឥតមានសេសសល់ឡើយ។

សាច់ឈាមរបស់សប្បុរសទាំងឡាយ ក៏ទីងត្រូវវិនាសទៅដូចគ្នាដែរ ប៉ុន្តែមុនពេលដែលសាច់ឈាមនោះវិនាសទៅ លោកបានប្រើប្រាស់វាដោយល្អ ធ្វើឲ្យរូបកាយរបស់លោក ក្លាយទៅជាទីអាស្រ័យនៃប្រាជ្ញាស្មារតី និងគុណធម៌ផ្សេងៗទៀតដោយច្រើន។

ព្រះសម្មាសម្ពុទ្ធតែងបានតិះដៀលនូវភាពអវិជ្ជា ឬការមិនចេះមិនដឹងជារឿយៗ ដូចដែលព្រះអង្គទ្រង់ត្រាស់សម្តែងនៅក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា ជរាវគ្គ ថា

**អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ**

**មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ។**

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ) ដូចជាគោបំរើ សាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ។

ម្យ៉ាងទៀត បើចំពោះអ្នកបួសវិញ មិនមែនបាន ឈ្មោះថាជាព្រះថេរៈ ដោយគ្រាន់តែបួសយូរ ឬដោយគ្រាន់តែមានសក់ស្កូវលើក្បាលឡើយ ដូចមាននិទានសង្ខេបថា

ក្នុងសម័យមួយមានព្រះថេរៈមួយព្រះអង្គ ព្រះនាមថា **លកុណ្ឌកភទ្ទិយៈ** លោកមានរាងតូច ហើយតឿៗ ថ្ងៃមួយលោកបានចូលគាល់ព្រះសាស្តា ក្រាបថ្វាយបង្គំគាល់បម្រើសមគួរហើយក៏ចេញទៅ ខណៈនោះ ភិក្ខុនៅព្រៃជាវត្តប្រមាណ៣០រូប ឃើញលោកហើយ ក៏បានចូលគាល់ព្រះសាស្តា ព្រះពុទ្ធអង្គត្រាស់សួរពួកភិក្ខុនៅព្រៃថា ពួកអ្នកឃើញព្រះថេរៈមួយរូបដែលទើបតែចេញទៅថ្មីៗទេ?

ពួកភិក្ខុឆ្លើយថា មិនឃើញទេ ឃើញតែសាមណេរមួយរូបព្រះអង្គៗ

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះមិនមែនជាសាមណេរទេ នុ៎ះជាព្រះថេរៈៗ

ពួកភិក្ខុពោលថា រូបរាងតូចណាស់ព្រះអង្គ ម្ដេចនឹងជាព្រះថេរៈកើត។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅថេរៈ ព្រោះហេតុតែជាមនុស្សចាស់ ឬព្រោះហេតុតែអង្គុយលើអាសនៈខ្ពស់ទេ ចំណែកអ្នកណាចាក់ធ្លុះសច្ចធម៌ទាំងឡាយហើយ តាំងនៅក្នុងភាវៈជាអ្នកមិនបៀតបៀនសត្វដទៃ អ្នកនេះទើបឈ្មោះថាជាថេរៈ ហើយទ្រង់ត្រាស់គាថាបន្ដទៀតថា

បុគ្គលមិនឈ្មោះថាជាថេរៈ ព្រោះហេតុតែ
មានសក់ស្កូវលើក្បាលទេ អ្នកមានវ័យចាស់ជរា
ហើយនោះ តថាគតហៅថាចាស់ទទេ ចំណែកអ្នក
ណាមាន សច្ចៈ ធម្មៈ អហិង្សា សញ្ញមៈ និងទមៈ
ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ មានប្រាជ្ញា
តថាគតហៅថា ជាព្រះថេរៈ។

បុគ្គលល្ងង់ខ្លៅ តែងមានខ្លួនឯងជាសត្រូវ ចំណែកបុគ្គលអ្នកមានប្រាជ្ញា ទើបមានខ្លួនឯងជាទីពឹង។

សូមមនុស្សគ្រប់គ្នា កុំចាស់ដូចជាគោចាស់ សូមបានចាស់ក្នុងនាមជាមនុស្សចាស់។

| |
|---|
| កើតមកជាមនុស្សតែខ្វះប្រាជ្ញា ខ្វះសីលសិក្ខាខ្វះការពិសោធន៍<br>ពីក្មេងដល់ចាស់ប៉ះនៅតែលោភ ចាស់ខ្លួនតែឆោតពិតដូចគោចាស់។<br>ភិក្ខុវជិរបញ្ញោ ស.ស.ឌ |



# កំណាព្យផ្សេងៗ

## គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋានៗ
មកចាប់ផ្ទៃមាតា ស្រីស្រីង្គារស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមីៗ
ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនាៗ
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័នៗ
កក្រើកផែនពសុធា មានទេវតាភប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនីៗ
ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី

ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកសួយ អភិសេកនឹងស្រីផ្គារ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្ងៃបានសុខា។
ស្តេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឲ្យព្រះរាជា ស្តេចជំពាក់ចិត្តពេកក្រៃ។
តែទ្រង់បានកាត់ផ្តាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្ងៃមួយគ្រាណា។
បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី

អាសាឍពេញបូណ៌មី ក្បត្រាថ្ងៃចេញបព្វជ្ជា។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្រកិរិយា គ្មាននរណាធ្វើដូចអី។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្មោះក្រុងមារ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្តាលដងព្រឹក្សព្រៃ។
គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្តើមពោលស្តីធម៌ទេសនា។
ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវកព្រះសាស្តា មានរហូតដល់សព្វថ្ងៃ។
ទាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ។

បីខែកន្លងទៅ　　មិនឈប់នៅយឺនយូរអើ
ដល់ថ្ងៃព្រះជិនស្រី　　ទ្រង់និព្វានចាកលោកា។
គឺក្នុងឆ្នាំនោះឯង　　មានការផ្សេងតែមាសា
គឺខែពិសាខនា　　ថ្ងៃអង្គារពេញបូណ៌មី។
ដោយអំណាចអានុភាព　　ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
ទឹកគុណព្រះមុនី　　សូត្រប្រវត្តិព្រះសាស្ដា។
សូមឲ្យសម្រេចបុណ្យ　　ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ　　សូមប្រាថ្នាជួបបណ្ឌិត។
សូមជួបព្រះសិអារ្យ　　ជាសាស្ដាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត　　សមដូចចិត្តប្រាថ្នាហោង។

ព.ស.២៥៤៦

# បទលើកទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មីភ្លឺស្រស់ល្អ ខៀវលឿងក្រហម
ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ម័គ្រស្មាគម
ជុំនុំគ្នាច្រើនអនេក ព្រមយករស្មី
ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា
នៃព្រះសម្ពុទ្ធធំចម្បង ចូរយើងរាល់គ្នា
យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា
សុទ្ធសឹងតែជាពុទ្ធសាសន៍ ត្រូវមានសាមគ្គី
ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឲ្យណាស់គ្រប់ៗគ្នា ។
សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត
រុងរឿងវិសុទ្ធថ្លៃថ្លា ហើយមានជ័យជោគ

ផ្កាយពេញលោកា ដោយជនជ្រះថ្លាភប់ច្រើនលាន។
មានចិត្តស្នេហា គោរពបូជា
ចំពោះព្រះធម៌ដ៏កល្យាណ ទាំងមនុស្សទេវតា
ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្ដីសុខ ។
យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត
កាន់ធម៌នឹងបានផុតទុក្ខ រួបរួមមេត្រី
ពីនេះទៅមុខ ទើបនឹងបានសុខក្សេមក្សាន្តត្រាណ។
ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត
ឆ្ពោះទៅកាន់ឋាននិព្វាន ជាទីផុតទុក្ខ
បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា។

*និពន្ធដោយ សម្ដេចព្រះសង្ឃរាជ*

**ជ.ណ ជោតញ្ញាណោ**

# បទសូត្រដាក់ទង់ព្រះពុទ្ធសាសនា

ក្រុមយើងអ្នកកាន់សាសនា
ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានចតុវណ្ណរង្សី
គឺព្រះរស្មីទាំងប្រាំមួយពណ៌ៗ
ផ្សាយចេញពីព្រះកាយទ្រង់
រុងរឿងបទ្ទិវង្គប្រសើរបវរ
ឆ្លៀលច្នាត់កាយចើតចាយល្អ
ទាំងប្រាំមួយពណ៌ស្រស់ល្អសោភាៗ
កំណើតនៃព្រះរស្មី
កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា
កាលដែលនៅជាព្រះពោធិសត្វៗ
រស្មីពណ៌ខៀវនោះណា
កាលធ្លៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍បាត់

កាលនៅជាក្សត្រនាមស្រីភិភស្រ្គ ។

រស្មីពណ៌លឿនភ្លឺថ្លា

កាលដែលទ្រង់អារសាច់ផែធ្វើមាស

បិទពុទ្ធរូបភ្លឺឱភាស

ព្រះឥន្ទជាឥមាសទ្រង់វ័យបណ្ឌិត ។

រស្មីក្រហមនោះណា

កាលដែលមាតាពស់ខាំស្លាប់ពិត

បទុមស្ម័បូរជីវិត

កាត់បេះដួចបិទធ្វើថ្នាំមាតា ។

រស្មីពណ៌សសុទ្ធសាធ

កាលដែលព្រះបាទវេស្សន្តរក្សត្រា

ឲ្យដីរសសោភា

ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញាណ ។

រស្មីពណ៌ដូចជើងហង្ស

កាលមាតាទ្រង់យក្ខចាប់យកបាន

វិជ្ជាធរអារសាច់ប្រាណ

ឲ្យយក្ខសាមានស្មុំបូរជីវិត ។

ស្មើពណ៌ផ្កែកពណ្ណរាយ

កាលជាទន្សាយឈ្មោះសោមបណ្ឌិត

ឲ្យទានសាច់ឈាមជីវិត

ដល់ឥន្ទព្រាហ្មណ៍ពិតជាអត់អាហារ ។

ស្មើខៀវលឿងក្រហម

សហង្សបាទព្រមភ្លឺផ្កែកអស្ចារ្យ

ត្រូវជាប្រាំមួយប្រការ

ទាំងចាស់កុមារចងចាំទុកអើយ ។

និពន្ធដោយ សម្ដេចព្រះសង្ឃរាជ

**ជ.ណ ជោតញ្ញាណោ**

# ស្តាប់តែម្ខាងនាំអន្តរាយ

ធម៌ឥស្សា នាំវាចា ឲ្យញុះញង់

បើជឿស្លុង ផុងស្មារតី កាត់ក្តីផ្អៀង

ស្តាប់តែម្ខាង ស្មានថាពិត មិនគិតផ្ទៀង

ភាពលំអៀង កៀងចូលផ្លូវ ទៅអបាយ ។

ដោយឧបាសិកា **ខិម លក្ខណា**

# លាភយស

ជុំពពុះទឹក    រាល់ពេលល្ងាចព្រឹក    ទឹកថ្លៃបណ្ដើរកូន

ពីឆ្ងាយឃើញពិត   ដល់ជិតបាត់សូន្យ   គ្មានអ្វីមាំមួន

គួរសង្ឃឹមបានៗ

អ្នកមានសក្តិខ្ពស់   មានទ្រព្យលាភយស ជនច្រើនប្រមាណ

ចុះចូលគ្រប់ទី   មូលមីរាប់អាន   ភ្ជាប់សាច់សន្តាន

ចងញាតិរចល់ៗ

កាលអ្នកធំជេរ    ស៊ូនៅធ្វើតែ   មិនដឹងមិនយល់

ចាញ់ប្រាបមាសប្រាក់ បុណ្យស័ក្តិថ្លើងថ្កល់ អ្នកអើយកុំឆ្ងល់

លាភយសគ្រប់មុខៗ

ដោយឧបាសិកា **ខិម លក្ខណា**

# ដំណើរធម្មយាត្រាទៅស្រីលង្កា

ស្រុកស្រីលង្កាសម្បូរបុណ្យ ទឹកដីអរហន្តលោកគង់នៅ
ព្រះពុទ្ធក៏ទ្រង់ធ្លាប់យាងទៅ ក្នុងសម័យជ្រោះជ្រៅត្រជាក់ចិត្ត។
តែទីដែលគួរឲ្យជ្រះថ្លា គឺព្រះសាស្តាស្តេចអាណិត
បន្សល់ព្រះធាតុថ្លៃពិតៗ ឲ្យពុទ្ធបរិស័ទទាំងប្រុសស្រី។
បានថ្វាយបង្គំធាតុពីរនោះឡើ ក្នុងសុវណ្ណមាលិកចេតិយ
បង្កើតសទ្ធាទាំងយប់ថ្ងៃ ដោយឧបនិស្ស័យផ្សំពីមុន។
កាលឃើញព្រះស្រីពោធិព្រឹក្ស ដាក់ចិត្តឲ្យនឹកព្រះមានបុណ្យ
ទ្រង់មានករុណាបញ្ញាគុណ វិសុទ្ធិគុណប្រៀបពុំបាន។
ពេលថ្វាយបង្គំព្រះទលាដ ឧណ្ហីសធាតុដ៏ថ្កើងថ្កាន
ហាក់ដូចអណ្តែតផុតពីស្ថាន ព្រោះមិននឹកស្មានបានមកដល់។
ទាំងអក្ខកធាតុថ្លៃបវរ ព្រះកេសធាតុក៏ក្របានយល់
អ្នកជួបពិតជាបុណ្យឲ្យផល ដែលមហាកុសលកើតព្រោះហេតុ។

ពុទ្ធស្ថានពិសេសមានមួយទៀត  គឺព្រះទន្តធាតុល្អត្រដែត
គង់ក្នុងកោដ្ឋមាសខ្ពស់មួយម៉ែត្រ  វន្ទាមិនឆ្អែតទេម្ចាស់ថ្លៃ។
ដំបូលប្រក់មាសល្អអស្ចារ្យ  ពិតានមានផ្កាម្តៃប្រាំបី
ធ្វើពីមាសសុទ្ធរុងរឿងក្រៃ  រចនាដោយដៃជាងប្រណីត។
ជាទីសក្ការៈបូជា  តម្កល់ទន្តាព្រះទ្រង់ឫទ្ធិ
ចង្កូមស្តាំក្រោមល្អពេកពិត  ភ្លឺផ្ទេកវិចិត្រដូចផ្កាយព្រឹក ។
ទីដែលបរិស័ទចាំរហូត  ភ្ញុំសុមនកូដល្អពន្លឺក
ខ្ពស់មែនតែនៅចាញ់ចិត្តនឹក  រលឹកដល់ស្នាមព្រះបាទថ្លៃ ។
មនុស្សម្នាជាច្រើនទាំងក្មេងចាស់  តស៊ូខ្លាំងណាស់ប្រឹងយប់ថ្ងៃ
អ្នកខ្លះវារឡើងពាក់ស្រោមដៃ  គិតថាទោះក្ស័យក៏មិនស្តាយ។
ចំណែកជនជាតិស្រីលង្កា  ស្រែកនមស្ការពីចម្ងាយ
ជាមួយពួកយើងយ៉ាងសប្បាយ ថាគេមកថ្វាយបង្គំព្រះ។
បរិស័ទខ្មែរយើងពឹងឈើច្រត់  ប្រសិនបើអត់មុខជាស្ងួះ
មិនងាយឡើងទេព្រះគុណម្ចាស់  ព្រោះភ្នំខ្ពស់ណាស់កប់វេហាស៍។

ពេលឡើងទៅដល់ចិត្តល្អស្អាត វន្ទាព្រះបាទដោយជ្រះថ្លា
ក្រាបថ្វាយបង្គំដល់សិរសា លើស្នាមបាទាព្រះពុទ្ធថ្លៃ។
យប់នោះត្រជាក់ធ្លាក់សន្សើម រងាញ័រញើមអាសូរក្រៃ
ដល់ជនគ្មានទីស្នាក់អាស្រ័យ សម្រាកផ្ទាល់ដីឥតអ្វីបាំង។
ពួកយើងជ្រៀតណែនក្នុងបន្ទប់ គង់គេងលក់ស៊ប់ព្រោះងុយខ្លាំង
ណាមួយឡើងក្អកអស់កម្លាំង ចាំតែភ្ញាក់ស្រាងនឹងអាលងើប។
ទៅថ្វាយបង្គំព្រះបាទា ពេលនមស្ការចិត្តរំភើប
ត្រេកអរសប្បាយហាក់ដូចទើប ងើបពីស្ថានក្រោមមកសួគ៌ា។
ពេលនោះអរុណចាំងរស្មី បច្ចូសសម័យយើងនាំគ្នា
ឈរចាំគោរពសូត្រវន្ទា បែរទៅបូព៌ាទិសថ្ងៃរះ។
តមកជនជាតិស្រីលង្កា ប្រទក្សិណបូជាដៃសំពះ
គោរពលើកទូលចង្ហាន់ព្រះ ថ្វាយចំពោះម្ចាស់ដ៏មានគុណ។
តាំងពីព្រះអង្គចូលនិព្វាន បរិស័ទថ្វាយទានជាប់និរន្តរ៍
ស្មើពុទ្ធសករាជជាងពីរពាន់ គិតទាំងក្រោយមុនរាល់ៗថ្ងៃ។

ចុងក្រោយឱនកាយថ្វាយបង្គំ លាទីឧត្តមបាទាថ្លៃ

រូបកាយឆ្ងាយពិតចិត្តអាល័យ មិនដឹងមានថ្ងៃណាជួបទៀតៗ

ម្ចាស់អើយទោះបីឃើញតែស្នាម ចិត្តនឹកជិតជាមមិនរវាត

សូមជួបត្រៃរតន៍គ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតខុសប្រាថ្នា។

ពេលចុះពីភ្នំក៏ដូចឡើង ឈឺចុកដៃជើងសព្វកាយា

ប៉ុន្តែកម្លាំងចិត្តជ្រះថ្លា សប្បាយអស្ចារ្យភ្លេចឈឺចាប់។

យើងលាកូឡុម្បូចេញឆ្ងាយហើយ រាត្រីចុងក្រោយហាក់ផ្តាំប្រាប់

ឲ្យនឹកលង្កាមហាកំណប់ នឹកយប់ចុះអ័ក្តពេលឡើងភ្នំ។

ពីថ្ងៃនេះទៅទោះនៅឆ្ងាយ វាចាចិត្តកាយខំបន្តុំ

ព្យាយាមស្តាប់ធម៌ហើយអប់រំ ធ្វើទានសីលផ្សំបូជាព្រះ។

ដោយឧបាសិកា **ខិម លក្ខណា**

# ទឹកស្រុកព្រះណាស់ !

ទឹកស្រុកព្រះណាស់មាស់ថ្លៃអើយ ទឹកមិនក្អេចឡើយក្រោយពីបាន
ទៅថ្វាយបង្គំទីជើងថាន សំរេជនីយដ្ឋានបូនកន្លែងៗ
ទាំងពេលបើកភ្នែកទាំងពេលដេក ទឹកឃើញជានិច្ចតែម្នាក់ឯង
ទឹកអស់សព្វហានព្រះអង្គតែង និមន្តខាត់ខែងគង់ប្រើប្រាស់ៗ
ទឹកខាំងជាងគេពុទ្ធគយា ដែលព្រះភគវាធ្លាប់បានត្រាស់
មហាពោធិ៍ក៏ស្ដូតាងបញ្ជាក់ច្បាស់ ឲ្យទឹកខាំងណាស់រៀងរាល់ថ្ងៃៗ
រួចទើបទឹកដល់ឈាបនដ្ឋាន និងទីនិព្វានព្រះចមថ្លៃ
ស្ដេចយាងនៅពេលបច្ចូសសម័យ សុក្រពេញបូណ៌មីខែពិសាខៗ
រួចហើយចិត្តទឹកទៅកន្លែង ព្រះអង្គសម្ដែងព្រះធម្មចក្ក
កំណើតព្រះធម៌ព្រះសង្ឃជាក់ ប្រោសអង្គសាវ័កបញ្ចវគ្គីយ៍ៗ
ឯទីប្រសូតក៏អស្ចារ្យ ឥន្ទព្រហ្មទេវតាមនុស្សមូលមីរ
ចាំថ្វាយបង្គំព្រះមុនី ទាំងមហាប្រឹថពីក៏រញ្ជួយៗ
ត្រេកអរទទួលព្រះមានបុណ្យ ប្រោសសត្វគ្រប់ជាន់បាត់ទុក្ខព្រួយ

ក្នុងលោកមានតែព្រះអង្គមួយ ជាទីពឹងជួយលុះអមតៈ។
រួចបានអនុមោទនាទឹកដល់ មហាបុណ្យកុសលព្រះកស្សបះ
ទូលពុទ្ធបាទថ្លៃលើសិរ្ស គោរពស្មោះស្ម័គ្រឥតគណនា។
រួចទឹកដល់គុណព្រះអរិយសង្ឃ លោកបានចងក្រងសង្គាយនា
ព្រះធម៌វិន័យថ្លៃមហិមា ឲ្យយើងរាល់គ្នាប្រតិបត្តិតាម។
ខំកាត់ពីឆ្ងាយថ្វាយបង្គំ តែស្ងាត់ជ្រងំឃើញតែស្នាម
សល់តែទីព្រៃវត្តអារាម ចិត្តរឹតជិតជាមទឹកព្រះពុទ្ធ។
អ្នកខ្លះទ្រាំបានទៅធម្មតា អ្នកខ្លះសោកាយំរន្ធត់
ស្តាយមិនបានជួបព្រះសុគត ព្រះទ័យបរិសុទ្ធស្អាតផូរផង់។
តែទោះមិនទាន់បានជួបក្តី ក៏ពុទ្ធវិន័យនៅត្រចង់
បើព្យាយាមរៀនដោយផ្ចិតផ្ចង់ អរិយមគ្គនាំត្រង់ទៅជួបព្រះ។

ដោយឧបាសិកា **ឱម លក្ខណា**

# អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ

ធម្មាចារ្យ គម្ភីរប្បញ្ញោ ទូច សុធី

ឧទ្ទេសាចារ្យ សីលសំវរោ ស៊ូ សាមុត

ភិក្ខុ កោសលប្បញ្ញោ ទូច ពិសិដ្ឋ

សាមណេរ បញ្ញាបរមោ ឈាត ប៊ុនឆាត

សាមណេរ ព្រហ្មឃោសកោ ឈិត ប៊ុនធឿន

សាមណេរ ញាណករុទ្ទោ សុខ វុធដែន

សាមណេរ ខន្តិធរោ ជឹម បូរិន

សាមណេរ ធម្មកាមតា វង ស៊ីង

ឧបាសក កែ ឈុនធី

# សៀវភៅធម៌

## ដែលរៀបរៀងដោយ ភិក្ខុវជិរប្បញ្ញោ សាន-សុជា

១.ដំណើរជីវិត

២.ព្រះធម្មបទ៣១គាថា

៣.អក្ខរវិធីនិងធម៌នមស្ការ

៤.លេកលោកធម៌

៥.ព្រះធម្មបទ៣០គាថា

៦.ប្រយោជន៍ ៣ ប្រការ

៧.ជីវិត (Life)

៨.បងប្អូនជួបគ្នាមួយគ្រាមានន័យ

៩.អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៤

១០.អភិធម្មសង្គណី តិកមាតិកាសង្ខេប

១១.ជីវិតពិតជាត្រូវការធម៌

១២.តើនរកមានដែរឬទេ ?

**ព្រះធម៌គឺជាផែនទីដ៏ជាក់លាក់សម្រាប់ជីវិត**

# ស្ថានីយវិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌
# សម្តែងដោយ ភិក្ខុវជិរប្បញ្ញោ សាន-សុជា

| ខេត្ត-ក្រុង | ស្ថានីយវិទ្យុ | វេលាផ្សាយ |
|---|---|---|
| ខេត្តសៀមរាប | FM 102.50 MHz | ៥.00 am ⇨ ៥.៣0 am រាល់ព្រឹក |
| ខេត្តកំពង់ធំ | FM 107.30 MHz | ៥.៣0 am ⇨ ៦.00 am រាល់ព្រឹក |
| រាជធានីភ្នំពេញ | FM 99.00 MHz | ៥.00 pm ⇨ ៥.៣0 pm រាល់ល្ងាច |
| ខេត្តពោធិ៍សាត់ | FM 100.50 MHz | ៦.៣0 pm ⇨ ៧.00 pm រាល់ល្ងាច |
| ក្រុងកំពង់សោម | FM 92.00 MHz | ៦.៣0 pm ⇨ ៧.00 pm រាល់ល្ងាច |
| ខេត្តកំពង់ចាម | FM 92.50 MHz | ៧.00 pm ⇨ ៧.៣0 pm រាល់ល្ងាច |
| ខេត្តកំពង់ធំ | FM 88.50 MHz | ៧.៣0 pm ⇨ ៨.00 pm រាល់យប់ |
| ខេត្តពោធិ៍សាត់ | FM 98.50 MHz | ៧.00 pm ⇨ ៨.00 pm យប់ថ្ងៃសីល |

**សុខា សទ្ធម្មទេសនា**

**ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ**